# បញ្ហានានាដែលមាននៅក្នុង
# រឿងក្តីរដ្ឋប្បវេណី



ក្រសួងយុត្តិធម៌ វិទ្យាស្ថានស្រាវជ្រាវទូទៅអំពីកិច្ចការច្បាប់
នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
Prof. Uchiyama Jun / Prof. Higashio Kazuyuki

*ចំពោះបញ្ហានានាដែលកើតមានឡើងក្នុងរឿងក្តីរដ្ឋប្បវេណីកម្ពុជា  តើត្រូវដោះស្រាយយ៉ាងដូចម្តេច ?*

*ទោះជាអានមាត្រានីមួយៗ ឬមើលសៀវភៅក៏ដោយ  ក៏មិនឃើញមានសរសេរចម្លើយច្បាស់លាស់សោះ ......។*



សូមជូនចម្លើយចំពោះចម្ងល់ទាំងនេះ !

ឥឡូវនេះ សូមលើកយកករណីសិក្សាដូចតទៅ មកពិចារណា !

# បើសិនជាជួបករណីដូចខាងក្រោមនេះ តើត្រូវធ្វើដូចម្តេច ?

1 បើសិនជាពាក្យបណ្តឹងមានចំណុចខ្វះ

2 បើសិនជាមានការទាមទារបន្ថែម ក្រោយពេលដាក់ពាក្យបណ្តឹង

3 បើសិនជាខ្លឹមសារនៃការទាមទាររបស់ដើមចោទនៅក្នុងពាក្យបណ្តឹងសរសេរមិនបានត្រឹមត្រូវ

4 បើសិនជាមានការប្តឹងជាន់គ្នា ចំពោះរឿងក្តីតែមួយ

5 បើសិនជាមានការដាក់ពាក្យសុំចាត់ចែងរក្សាការពាររដ្ឋប្បវេណីក្រោយពេលសាលក្រមសម្រេចអង្គសេចក្តីបានចូលជាស្ថាពរ

6 បើសិនជាមិនមានការគោរពអំឡុងពេលប្តឹងឧបាស្រ័យទេ

※នៅក្នុងស្លៃដ៍ទាំងនេះ បញ្ញត្តិច្បាប់ណាដែលមិនបានបញ្ជាក់ឈ្មោះច្បាប់ច្បាស់លាស់ទេ គឺជាបញ្ញត្តិនៃ“ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា”។

# ករណីសិក្សារួម



ដី L

កម្មសិទ្ធិករ:Y

ឈ្មោះក្នុងគោលបញ្ជីដីធ្លី:Y

នៅថ្ងៃទី1 ខែមករា ឆ្នាំ2016 X បានទិញដី L ពី Y ក្នុងតម្លៃ10000 USD។



X



Y

Y មិនព្រមចុះបញ្ជីផ្ទេរកម្មសិទ្ធិដី L ទេ។

# ករណីសិក្សារួម



ដី L

កម្មសិទ្ធិករ : Y

ឈ្មោះក្នុងគោលបញ្ជីដីធ្លី : Y



អ្នកឯងត្រូវចុះបញ្ជីផ្ទេរកម្មសិទ្ធិ
ដី L មកឱ្យខ្ញុំ !
(ដាក់ពាក្យបណ្ដឹង)



X → Y

ការទាមទារ : ទាមទារឱ្យផ្ទេរកម្មសិទ្ធិដោយផ្អែក
លើកិច្ចសន្យាលក់ទិញ

# បើសិនជាជួបករណីដូចខាងក្រោមនេះ តើត្រូវធ្វើដូចម្ដេច ?

*1 បើសិនជាពាក្យបណ្ដឹងមានចំណុចខ្វះ*

2 បើសិនជាមានការទាមទារបន្ថែម ក្រោយពេលដាក់ពាក្យបណ្ដឹង

3 បើសិនជាខ្លឹមសារនៃការទាមទាររបស់ដើមចោទនៅក្នុងពាក្យបណ្ដឹង សរសេរមិនបានត្រឹមត្រូវ

4 បើសិនជាមានការប្ដឹងជាន់គ្នាចំពោះរឿងក្ដីតែមួយ

5 បើសិនជាមានការដាក់ពាក្យសុំចាត់ចែងរក្សាការពាររដ្ឋប្បវេណីក្រោយពេលសាលក្រមសម្រេចអង្គសេចក្ដីបានចូលជាស្ថាពរ

6 បើសិនជាមិនមានការគោរពអំឡុងពេលប្ដឹងឧបាស្រ័យទេ

1 បើសិនជាពាក្យបណ្ដឹងមានចំណុចខ្វះ

# “លំហូរនៃនីតិវិធីក្រោយពេលដាក់ពាក្យបណ្ដឹង(1)”

ដើមចោទ : ដាក់ពាក្យបណ្ដឹង(មាត្រា 75 កថាខ័ណ្ឌទី1)

↓

តុលាការ : ទទួលពាក្យបណ្ដឹង

↓

តុលាការ : ពិនិត្យពាក្យបណ្ដឹងក្រោយពេលទទួល

# "លំហូរនៃនីតិវិធីក្រោយពេលដាក់ពាក្យបណ្តឹង(1)"

ដើមចោទ :  ដាក់ពាក្យបណ្តឹង(មាត្រា 75 កថាខ័ណ្ឌទី1)

↓

តុលាការ :  ទទួលពាក្យបណ្តឹង

↓

តុលាការ :  ពិនិត្យពាក្យបណ្តឹងក្រោយពេលទទួល

# ការដាក់ និង ទទួលពាក្យបណ្ដឹង

X បានដាក់ពាក្យបណ្ដឹងទៅតុលាការ។

បើសិនជាពាក្យបណ្ដឹងត្រូវបានដាក់ តុលាការមិនអាចប្រកែកមិនទទួលបានឡើយ។
នៅក្នុងពាក្យបណ្ដឹងមានចំណុចដែលចាំបាច់ត្រូវសរសេរបញ្ជាក់ (មាត្រា75 កថាខ័ណ្ឌទី2)។

# ការដាក់ និង ទទួលពាក្យបណ្ដឹង

ចំណុចដែលចាំបាច់ត្រូវសរសេរបញ្ជាក់ក្នុងពាក្យបណ្ដឹង(មាត្រា 75 កថាខ័ណ្ឌទី2)

ក: ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី

ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់

ខ: ខ្លឹមសារនៃសាលក្រមដែលទាមទារ

ឧ.) "បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់១ម៉ឺនដុល្លារអាមេរិកទៅឱ្យដើមចោទ"

អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ

ឧ.) កាលបរិច្ឆេទនៃកិច្ចសន្យាលក់ទិញ ទឹកប្រាក់ វត្ថុដែលជាកម្មវត្ថុនៃបណ្ដឹង ជាដើម

---

មាត្រា 75 កថាខ័ណ្ឌទី2

នៅក្នុងលិខិតនៃពាក្យបណ្ដឹង ត្រូវសរសេរបញ្ជាក់នូវចំណុចខាងក្រោមនេះ :

ក-ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

ខ-ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញនិង អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ ។

មាត្រា 78 កថាខ័ណ្ឌទី1

ក្នុងករណីដែលពាក្យបណ្ដឹងផ្ទុយនឹងបញ្ញត្តិនៃកថាខ័ណ្ឌទី ២ មាត្រា ៧៥ (របៀបដាក់ពាក្យបណ្ដឹង និង ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្ដឹង) ខាងលើនេះ តុលាការត្រូវកំណត់អំឡុងពេលសមរម្យ និង បង្គាប់ឱ្យកែតម្រូវចំណុចខ្វះ ចំពោះពាក្យបណ្ដឹងនោះ ក្នុងអំឡុងពេលនោះ ។ (ក្រៅពីនេះរំលងចោល)

# ការដាក់ និង ទទួលពាក្យបណ្តឹង

**ពាក្យបណ្តឹង**

"ភាគី"

ដើមចោទ ○○○(អាស័យដ្ឋាន)

X (ឈ្មោះ)

ចុងចម្លើយ △△△(អាស័យដ្ឋាន)

Y (ឈ្មោះ)

(តទៅទំព័របន្ទាប់)

# ការដាក់ និង ទទួលពាក្យបណ្តឹង

## ពាក្យបណ្តឹង

"ខ្លឹមសារនៃសាលក្រមដែលទាមទារ"

បង្គាប់ឱ្យចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងអស់នៃដីដែលមានចុះក្នុងបញ្ជីឧបសម្ព័ន្ធស្តីពីអចលនវត្ថុទៅឱ្យដើមចោទ ដោយមូលហេតុលក់ទិញចុះថ្ងៃទី1 ខែមករា ឆ្នាំ2016

"អង្គហេតុ"

នៅថ្ងៃទី1 ខែមករា ឆ្នាំ2016 ដើមចោទXបានទិញដីដែលមានចុះក្នុងបញ្ជីឧបសម្ព័ន្ធស្តីពីអចលនវត្ថុ ពីចុងចម្លើយ ក្នុងតម្លៃ១ម៉ឺនដុល្លារអាមេរិក។ X និង Yបានបង្កើតកិច្ចសន្យាលក់ទិញនេះដោយលិខិតយថាភូត។

# “លំហូរនៃនីតិវិធីក្រោយពេលដាក់ពាក្យបណ្តឹង (1)”

ដើមចោទ : ដាក់ពាក្យបណ្តឹង(មាត្រា 75 កថាខ័ណ្ឌទី1)

↓

តុលាការ : ទទួលពាក្យបណ្តឹង

↓

តុលាការ : ពិនិត្យពាក្យបណ្តឹងក្រោយពេលទទួល

# ការពិនិត្យពាក្យបណ្ដឹងក្រោយពេលទទួល

បើសិនជាពាក្យបណ្ដឹងមានចំណុចខ្វះ មិនអាចជម្រុញនីតិវិធីឲ្យទៅមុខបានឡើយ។

ហេតុនេះហើយ នៅប្រទេសជប៉ុន បន្ទាប់ពីបានទទួលពាក្យបណ្ដឹងហើយ គេធ្វើការពិនិត្យយ៉ាងតិចក៏៣ដងដែរ។

1) ក្រឡាបញ្ជីដែលទទួល
2) ក្រឡាបញ្ជីទទួលបន្ទុក
3) ចៅក្រមទទួលបន្ទុក

# ការពិនិត្យពាក្យបណ្តឹងក្រោយពេលទទួល

ពេលធ្វើការពិនិត្យពាក្យបណ្តឹង យ៉ាងតិចណាស់ក៏ត្រូវពិនិត្យនូវចំណុចខាងក្រោមនេះ ជាដើមដែរ

- “ខ្លឹមសារនៃសាលក្រមដែលទាមទារ”
- “អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ”
- ពន្ធ ជាអាទិ៍

បើសិនជាគ្រប់លក្ខណៈ តុលាការនឹងជម្រុញនីតិវិធីទៅមុខទៀត។

# ការពិនិត្យពាក្យបណ្ដឹងក្រោយពេលទទួល

ការធានានូវសិទ្ធិពឹងពាក់តុលាការ(មាត្រា2 កថាខ័ណ្ឌទី2) ការសម្រេចនូវការប្រព្រឹត្តទៅនៃរឿងក្ដីរដ្ឋប្បវេណីដោយមានភាពយុត្តិធម៌និងឆាប់រហ័ស

តុលាការត្រូវដឹកនាំនីតិវិធីឱ្យបានឆាប់រហ័សក្រោយពេលបានទទួលពាក្យបណ្ដឹង។

# ការពិនិត្យពាក្យបណ្ដឹងក្រោយពេលទទួល

លំអិតគឺ

- បន្ទាប់ពីបានធ្វើការពិនិត្យពាក្យបណ្ដឹងនិងការបង់ពន្ធហើយ តុលាការត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលឱ្យឆាប់រហ័ស (មាត្រា80 កថាខ័ណ្ឌទី1)។
- ជាគោលការណ៍ ត្រូវកំណត់កាលបរិច្ឆេទនេះក្នុងអំឡុងពេល ៣០ ថ្ងៃ បន្ទាប់ពីថ្ងៃដែលពាក្យបណ្ដឹងត្រូវបានដាក់(មាត្រាដដែល កថាខ័ណ្ឌទី2)។

# ចំណុចខ្វះនៃពាក្យបណ្ដឹង

បន្ទាប់ពីធ្វើការពិនិត្យពាក្យបណ្ដឹងទៅ គេអាចរកឃើញចំណុចខ្វះក្នុងពាក្យបណ្ដឹង។

តើអាចមានចំណុចខ្វះនៃពាក្យបណ្ដឹងដូចម្ដេចដែរ? សូមលើកយក "ករណីសិក្សារួម" មកពិចារណា។

# “លំហូរនៃនីតិវិធីក្រោយពេលដាក់ពាក្យបណ្ដឹង (2)”



# ពាក្យបណ្ដឹងដែល X បានសរសេរ (1)

## ពាក្យបណ្ដឹង

"ភាគី"

ដើមចោទ ○○○(អាស័យដ្ឋាន)

X (ឈ្មោះ)

ចុងចម្លើយ △△△(អាស័យដ្ឋាន)

Z (ឈ្មោះ) ※ឈ្មោះត្រឹមត្រូវគឺ "Y"

Xបានសរសេរពាក្យបណ្ដឹងដូចខាងលើនេះ។

# ពាក្យបណ្តឹងដែល X បានសរសេរ (1)

នៅក្នុងពាក្យបណ្តឹង ត្រូវសរសេរ "ឈ្មោះរបស់ភាគី" (មាត្រា 75 កថាខ័ណ្ឌទី2 ចំណុច ក.)។

↓

នៅក្នុងពាក្យបណ្តឹងរបស់ X "ឈ្មោះរបស់ចុងចម្លើយ" ខុស។

# ពាក្យបណ្តឹងដែល X បានសរសេរ (1)

នៅដំណាក់កាលទទួលពាក្យបណ្តឹង តុលាការអាចនឹងមិនចាប់ភ្លឹកថា មានកំហុសក្នុងការសរសេរឈ្មោះ

- ដោយសារតែពុំមានវិធីធ្វើការបញ្ជាក់ឈ្មោះត្រឹមត្រូវរបស់ចុងចម្លើយ។

អាចចាប់ភ្លឹកអំពីកំហុសក្នុងការសរសេរឈ្មោះនេះ នៅពេលដូចតទៅ

- មិនអាចផ្ញើការបញ្ជូនពាក្យបណ្តឹង ហើយគេបានសួរបញ្ជាក់ដើមចោទម្តងទៀត ទើបដឹងថា មានកំហុសក្នុងការសរសេរឈ្មោះចុងចម្លើយនោះ។
- បានដឹងអំពីកំហុសក្នុងការសរសេរឈ្មោះ តាមរយៈឯកសារដែលបានដាក់ដោយចុងចម្លើយ Y។

# ពាក្យបណ្ដឹងដែល X បានសរសេរ (2)

## ពាក្យបណ្ដឹង

“ភាគី”

ដើមចោទ ○○○(អាស័យដ្ឋាន)

X (ឈ្មោះ)

ចុងចម្លើយ □□□(អាស័យដ្ឋាន) ※ឈ្មោះត្រឹមត្រូវគឺ “△△△”

Y (ឈ្មោះ)

X បានសរសេរពាក្យបណ្ដឹងដូចខាងលើនេះ។

# ពាក្យបណ្ដឹងដែល X បានសរសេរ (2)

នៅក្នុងពាក្យបណ្ដឹង ត្រូវសរសេរ "អាស័យដ្ឋានរបស់ភាគី" (មាត្រា75 កថាខ័ណ្ឌទី2 ចំណុច ក.)។

⬇

នៅក្នុងពាក្យបណ្ដឹងរបស់ X "អាស័យដ្ឋានរបស់ Y" ខុស។

※មូលហេតុដែលតុលាការបានចាប់ភ្លឹកទៅលើកំហុសអាស័យដ្ឋាន គឺដូចគ្នានឹងករណីកំហុសឈ្មោះដែរ។

# ពាក្យបណ្តឹងដែល X បានសរសេរ (3)

## ពាក្យបណ្តឹង

"ខ្លឹមសារនៃសាលក្រមដែលទាមទារ"

បង្គាប់ឱ្យចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងអស់ពាក់ព័ន្ធនឹងដីដែលដើមចោទបានទិញ ទៅឱ្យដើមចោទ។

"អង្គហេតុ"

នៅថ្ងៃទី1 ខែមករា ឆ្នាំ2016 ដើមចោទ X បានទិញដី L ពីចុងចម្លើយ។ X និងY បានបង្កើតកិច្ចសន្យាលក់ទិញនេះដោយលិខិតយថាភូត។

X បានសរសេរពាក្យបណ្តឹងដូចខាងលើនេះ។

# ពាក្យបណ្ដឹងដែល X បានសរសេរ (3)

នៅក្នុងពាក្យបណ្ដឹង ត្រូវសរសេរអំពី “ខ្លឹមសារនៃសាលក្រមដែលទាមទារ” (មាត្រា75 កថាខ័ណ្ឌទី2 ចំណុច ខ.)។

ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីខ្លឹមសារនៃ “សាលក្រមដែលទាមទារ” ដើម្បីចេញសាលក្រម។

ក៏ប៉ុន្តែ

- ការសរសេរថា “ដីដែលដើមចោទបានទិញ” គឺមិនច្បាស់ លាស់ទេ មិនដឹងជាទាមទារឱ្យចុះបញ្ជីផ្ទេរកម្មសិទ្ធិដីមួយណាទេ។
- មូលហេតុនៃការចុះបញ្ជីផ្ទេរកម្មសិទ្ធិក៏មិនច្បាស់លាស់ដែរ។

# ពាក្យបណ្ដឹងដែល X បានសរសេរ (4)

**ពាក្យបណ្ដឹង**

"ខ្លឹមសារនៃសាលក្រមដែលទាមទារ"
បង្គាប់ឱ្យចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងអស់នៃដីដែលមានចុះក្នុងបញ្ជីឧបសម្ព័ន្ធស្ដីពីអចលនវត្ថុទៅឱ្យដើមចោទ ដោយមូលហេតុលក់ទិញ

"អង្គហេតុ"
ដើមចោទ X បានទិញដីដែលមានចុះក្នុងបញ្ជីឧបសម្ព័ន្ធស្ដីពីអចលនវត្ថុ ពីចុងចម្លើយ។ X និង Y បានបង្កើតកិច្ចសន្យាលក់ទិញនេះដោយលិខិតយថាភូត។

X បានសរសេរពាក្យបណ្ដឹងដូចខាងលើនេះ។

# ពាក្យបណ្ដឹងដែល X បានសរសេរ (4)

នៅក្នុងពាក្យបណ្ដឹង ត្រូវសរសេរអំពី "អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ" ( មាត្រា75 កថាខ័ណ្ឌទី2 ចំណុច ខ.)។ "អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ" គឺជាចំណុចចាំបាច់ដើម្បីបញ្ជាក់អំពីកម្មវត្ថុនៃការជំនុំជម្រះ។

- បើសិនជាមិនអាចបញ្ជាក់បានទេ ទំហំដែលចាត់ទុកថាជាបណ្ដឹងជាន់គ្នា (មាត្រា83) ឬទំហំនៃអាជ្ញាអស់ជំនុំ (មាត្រា194) មិនច្បាស់លាស់ទេ។



ក៏ប៉ុន្តែ

- បើសិនជាគ្រាន់តែសរសេរថា "ការលក់ទិញ" គឺមិនដឹងច្បាស់លាស់ថា ជាការផ្អែកលើកិច្ចសន្យាលក់ទិញណាមួយទេ។

# ពាក្យបណ្ដឹងដែល X បានសរសេរ (4)

ការទាមទាររបស់ X នេះ ផ្អែកទៅលើកិច្ចសន្យាលក់ទិញ។

រវាង X និង Y អាចមានកិច្ចសន្យាជាច្រើន។



# ពាក្យបណ្ដឹងដែល X បានសរសេរ (4)

"ឧ.ទី1"

រវាងXនិងY ថ្ងៃបង្កើតកិច្ចសន្យាតែមួយ ប៉ុន្តែអាចមានកិច្ចសន្យាប្រភេទផ្សេងគ្នាក៏មានដែរ។

1) កិច្ចសន្យា<u>លក់ទិញដី</u>ចុះថ្ងៃទី1 ខែតុលា ឆ្នាំ2015
2) កិច្ចសន្យា<u>ខ្ចីបរិភោគ</u>ចុះថ្ងៃទី1 ខែតុលា ឆ្នាំ2015
3) កិច្ចសន្យា<u>លក់ទិញរថយន្ត</u>ចុះថ្ងៃទី1 ខែតុលា ឆ្នាំ2015

ត្រូវបញ្ជាក់ឱ្យច្បាស់លាស់ថា តើជាការទាមទារដោយផ្អែកលើកិច្ចសន្យាណាមួយ។

# ពាក្យបណ្តឹងដែល X បានសរសេរ (4)

"ឧ.ទី2"

រវាងXនិងY អាចមានកិច្ចសន្យាប្រភេទដូចគ្នា តែថ្ងៃបង្កើតកិច្ចសន្យាផ្សេងគ្នាក៏មានដែរ។

1) កិច្ចសន្យាលក់ទិញដីចុះថ្ងៃទី1 ខែតុលា ឆ្នាំ2015
2) កិច្ចសន្យាលក់ទិញដីចុះថ្ងៃទី1 ខែមករា ឆ្នាំ2016
3) កិច្ចសន្យាលក់ទិញដីចុះថ្ងៃទី1 ខែមេសា ឆ្នាំ2016
4) កិច្ចសន្យាលក់ទិញដីចុះថ្ងៃទី1 ខែកក្កដា ឆ្នាំ2016

ត្រូវបញ្ជាក់ឱ្យច្បាស់លាស់ថា តើជាការទាមទារដោយផ្អែកលើកិច្ចសន្យាណាមួយ។

# ពាក្យបណ្ដឹងដែល X បានសរសេរ (4)

ក្នុងករណីនៃការទាមទារដោយផ្អែកលើកិច្ចសន្យា ចាំបាច់ត្រូវធ្វើការបញ្ជាក់ថា ជាកិច្ចសន្យាណាមួយតាមកត្តាដូចតទៅ។

- ភាគី
- កាលបរិច្ឆេទនៃកិច្ចសន្យា
- ខ្លឹមសារនៃកិច្ចសន្យា(ការលក់ទិញ, ការខ្ចីបរិភោគ ជាអាទិ៍)

នៅក្នុងបណ្ដឹងរបស់ X មិនមានការបញ្ជាក់ថា ជាការទាមទារដោយផ្អែកលើកិច្ចសន្យាណាមួយទេ។ នេះគឺជាការសរសេរអំពី "អង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ" មិនបានពេញលេញ។

# ចំណុចខ្វះនៃពាក្យបណ្តឹង

បើសិនជាមានចំណុចខ្វះដូចខាងលើនេះ  តើតុលាការត្រូវចាត់ចែងយ៉ាងដូចម្តេច ?

តុលាការត្រូវទាមទារឱ្យធ្វើការ "កែតម្រូវ"។

# ចំណុចខ្វះនៃពាក្យបណ្តឹង

វិធីទាមទារឱ្យកែតម្រូវ

1) <u>ប្រាប់ឱ្យកែតម្រូវ</u>
តុលាការទាមទារឱ្យភាគីធ្វើការកែតម្រូវដោយស្ម័គ្រចិត្ត។

2) <u>បង្គាប់ឱ្យកែតម្រូវ</u>
តុលាការបង្គាប់ឱ្យភាគីធ្វើការកែតម្រូវ។

ក្នុងករណីដែលរកឃើញមានបញ្ហានៅពេលពិនិត្យពាក្យបណ្តឹង ត្រូវចាត់ចែងដូចតទៅ ឱ្យបានទាន់ពេលវេលា

- ប្រាប់ឱ្យកែតម្រូវ
- បង្គាប់ឱ្យកែតម្រូវ

# ចំណុចខ្វះនៃពាក្យបណ្ដឹង

វិធីកែតម្រូវជាក់ស្ដែង

(ឧ.) . ឆូតកន្លែងខុស សរសេរឡើងវិញ ហើយបោះត្រាលើកន្លែងកែតម្រូវ

. ដាក់ឯកសារមួយផ្សេងសរសេរបញ្ជាក់កន្លែងខុស

តើត្រូវជ្រើសរើសវិធីណាមួយ គឺត្រូវពិចារណាទៅតាមសារៈសំខាន់នៃខ្លឹមសារដែលកែតម្រូវ ឬចំនួនកន្លែងមានកំហុស។

- ប្ដូរពាក្យបណ្ដឹង
- ដាក់ពាក្យបណ្ដឹងសាជាថ្មី

ជាបឋម គេច្រើនតែប្រាប់ឱ្យកែតម្រូវ ហើយបើសិនជាភាគីមិនធ្វើតាមទេ ត្រូវចេញដីកាបង្គាប់ឱ្យកែតម្រូវ។

# “លំហូរនៃនីតិវិធីក្រោយពេលដាក់ពាក្យបណ្ដឹង (2)”



# ចំណុចខ្វះនៃពាក្យបណ្តឹង

បើសិនជាដើមចោទបានកែតម្រូវហើយ ត្រូវជម្រុញនីតិវិធីតាមធម្មតា។

លំអិតគឺ មានដូចក្នុងស្លៃដ៍ទី15 ៖

- ធ្វើការកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលឱ្យឆាប់រហ័ស(មាត្រា80 កថាខ័ណ្ឌទី1)។
- ជាគោលការណ៍ ត្រូវកំណត់កាលបរិច្ឆេទនេះក្នុងអំឡុងពេល ៣០ ថ្ងៃ បន្ទាប់ពីថ្ងៃដែលពាក្យបណ្តឹងត្រូវបានដាក់(មាត្រាដដែល កថាខ័ណ្ឌទី2)។

# “លំហូរនៃនីតិវិធីក្រោយពេលដាក់ពាក្យបណ្ដឹង (2)”



# ចំណុចខ្វះនៃពាក្យបណ្ដឹង

ប្រសិនបើដើមចោទមិនកែតម្រូវទេ តុលាការត្រូវលើកពាក្យបណ្ដឹងចោល(មាត្រា78 កថាខ័ណ្ឌទី2)។

ចំពោះការលើកបណ្ដឹងចោលនេះ X អាចប្ដឹងជំទាស់បាន(មាត្រា78 កថាខ័ណ្ឌទី3, ពីមាត្រា301～)។

- ក្នុងករណីដែល X មិនប្ដឹងជំទាស់ទេ ការលើកបណ្ដឹងចោលនឹងចូលជាស្ថាពរ ហើយរឿងក្ដីនេះនឹងត្រូវបានបញ្ចប់។
- បើសិនជាមានបណ្ដឹងជំទាស់ សាលាឧទ្ធរណ៍នឹងធ្វើការវិនិច្ឆ័យជាថ្មី។

# “លំហូរនៃនីតិវិធីក្រោយពេលដាក់ពាក្យបណ្ដឹង (2)”



# សង្ខេបនៃ "លំហូរនៃនីតិវិធីក្រោយពេលដាក់ពាក្យបណ្ដឹង (2)"



# ឧទាហរណ៍នៃពាក្យបណ្តឹងសរសេរបានល្អ និង ពាក្យបណ្តឹងសរសេរមិនបានល្អ

ខាងលើនេះគឺជានីតិវិធីក្រោយពេលទទួលពាក្យបណ្តឹង។

ក្នុងនោះ របៀបសរសេរ "ខ្លឹមសារនៃសាលក្រមដែលទាមទារ" និង "អង្គហេតុដើម្បីបញ្ជាក់នូវការទាមទារ" ពិបាកណាស់ ហើយជាពិសេសសំខាន់ទៀតផង។

ដូច្នេះ សូមលើកយកឧទាហរណ៍នៃពាក្យបណ្តឹងសរសេរបានល្អ និង ពាក្យបណ្តឹងសរសេរមិនបានល្អ នៃប្រភេទរឿងក្តីផ្សេងទៀត ក្រៅពី "ករណីសិក្សារួម" មកពិចារណាមើល។

# ចំណុចខ្វះនៃ "ខ្លឹមសារនៃសាលក្រមដែលទាមទារ"

តើឧទាហរណ៍ខាងក្រោមនេះ យ៉ាងណាដែរ ?

- "បង្គាប់ឱ្យចុងចម្លើយសងប្រាក់កម្ចីទៅឱ្យដើមចោទ"
- "បង្គាប់ឱ្យចុងចម្លើយបង់ថ្លៃលក់ទិញទៅឱ្យដើមចោទ"
- "បង្គាប់ឱ្យចុងចម្លើយប្រគល់រថយន្តដែលដើមចោទបានទិញទៅឱ្យដើមចោទ"
- "បង្គាប់ឱ្យចុងចម្លើយរើចេញហើយប្រគល់ដីដែលជាកម្មសិទ្ធិរបស់ដើមចោទទៅឱ្យដើមចោទ"

សាលក្រមដែលទាមទារខាងលើនេះ មួយណាក៏មិនច្បាស់លាស់ដែរ ដូច្នេះចាំបាច់ត្រូវតែ "កែតម្រូវ"។

# ចំណុចខ្វះនៃ "ខ្លឹមសារនៃសាលក្រមដែលទាមទារ"

ចូរធ្វើការកែតម្រូវពាក្យបណ្ដឹង។

- "បង្គាប់ឱ្យចុងចម្លើយសងប្រាក់កម្ចីទៅឱ្យដើមចោទ"
- "បង្គាប់ឱ្យចុងចម្លើយបង់ថ្លៃលក់ទិញទៅឱ្យដើមចោទ"

- "បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់<u>១ម៉ឺនដុល្លារអាមេរិក</u>ទៅឱ្យដើមចោទ"។

※ទឹកប្រាក់ត្រូវបានបញ្ជាក់ច្បាស់លាស់។

# ចំណុចខ្វះនៃ "ខ្លឹមសារនៃសាលក្រមដែលទាមទារ"

## ចូរធ្វើការកែតម្រូវពាក្យបណ្ដឹង។

- "បង្គាប់ឱ្យចុងចម្លើយប្រគល់រថយន្តដែលដើមចោទបានទិញទៅឱ្យដើមចោទ"

- "បង្គាប់ឱ្យចុងចម្លើយ<u>ប្រគល់រថយន្តដែលមានចុះក្នុងបញ្ជីឧបសម្ព័ន្ធស្ដីពីរថយន្ត</u>ទៅឱ្យដើមចោទ។"

  ※រថយន្តត្រូវបានបញ្ជាក់ច្បាស់លាស់

# ចំណុចខ្វះនៃ "ខ្លឹមសារនៃសាលក្រមដែលទាមទារ"

## ចូរធ្វើការកែតម្រូវពាក្យបណ្តឹង។

- "បង្គាប់ឱ្យចុងចម្លើយរើចេញហើយប្រគល់ដីដែលជាកម្មសិទ្ធិរបស់ដើមចោទទៅឱ្យដើមចោទ"

- "បង្គាប់ឱ្យចុងចម្លើយ<u>រើចេញហើយប្រគល់ដីដែលមានចុះក្នុងបញ្ជីឧបសម្ព័ន្ធស្តីពីអចលនវត្ថុ</u>ទៅឱ្យដើមចោទ"

※ដីត្រូវបានបញ្ជាក់ច្បាស់លាស់។

# ករណីនៃការទាមទារដោយផ្អែកលើកម្មសិទ្ធិ

នៅក្នុង "ករណីសិក្សារួម" គឺជាករណីទាមទារដោយផ្អែកលើ "កិច្ចសន្យា"។

ចុះបើករណីទាមទារដោយផ្អែកលើ "កម្មសិទ្ធិ" វិញ តើយ៉ាងណាដែរ?
ចូរពិចារណាករណីដូចតទៅ។

# ករណីនៃការទាមទារដោយផ្អែកលើកម្មសិទ្ធិ



ដី M

កម្មសិទ្ធិករ : P

អ្នកកាន់កាប់ : D



អ្នកឯងត្រូវរើចេញ ហើយ
ប្រគល់ដីមកវិញ !
(ដាក់ពាក្យបណ្ដឹង)



P → D

ការទាមទារ : ទាមទារឱ្យប្រគល់ដីដោយផ្អែកលើកម្មសិទ្ធិ

# ករណីនៃការទាមទារដោយផ្អែកលើកម្មសិទ្ធិ

លើដីមួយ គេអាចបង្កើតកម្មសិទ្ធិបានតែមួយទេ  ហេតុនេះហើយ វាខុសគ្នានឹងករណីស្តីពីកិច្ចសន្យា មិនចាំបាច់សរសេរបញ្ជាក់អំពី "ថ្ងៃ ○○ ខែ○○"ទេ។

តាមរយៈការបញ្ជាក់ច្បាស់លាស់អំពីវត្ថុដែលជាកម្មវត្ថុ (ដី) គេអាចបញ្ជាក់អំពីខ្លឹមសារនៃការទាមទារបាន។
ការបញ្ជាក់ដីធ្លី ត្រូវធ្វើឡើងដោយផ្អែកលើសៀវភៅគោលបញ្ជីដីធ្លី។

# ករណីនៃការទាមទារដោយផ្អែកលើកម្មសិទ្ធិ

"ឧទាហរណ៍នៃការសរសេរពាក្យបណ្ដឹង"

## ពាក្យបណ្ដឹង

"ខ្លឹមសារនៃសាលក្រមដែលទាមទារ"
បង្គាប់ឱ្យចុងចម្លើយរើចេញ ហើយប្រគល់ដីដែលមានចុះក្នុងបញ្ជីឧបសម្ព័ន្ធស្ដីពីអចលនវត្ថុ ទៅឱ្យដើមចោទ។

"អង្គហេតុ"
ដើមចោទ X មានកម្មសិទ្ធិលើដីដែលមានចុះក្នុងបញ្ជីឧបសម្ព័ន្ធស្ដីពីអចលនវត្ថុ រីឯចុងចម្លើយវិញ គ្មានសិទ្ធិអ្វីទាំងអស់ តែគាត់បានកាន់កាប់ដីនោះតាមទំនើងចិត្តរបស់គាត់។

# បើសិនជាជួបករណីដូចខាងក្រោមនេះ តើត្រូវធ្វើដូចម្តេច ?

1 បើសិនជាពាក្យបណ្តឹងមានចំណុចខ្វះ

*2 បើសិនជាមានការទាមទារបន្ថែម ក្រោយពេលដាក់ពាក្យបណ្តឹង*

3 បើសិនជាខ្លឹមសារនៃការទាមទាររបស់ដើមចោទនៅក្នុងពាក្យបណ្តឹង សរសេរមិនបានត្រឹមត្រូវ

4 បើសិនជាមានការប្តឹងជាន់គ្នា ចំពោះរឿងក្តីតែមួយ

5 បើសិនជាមានការដាក់ពាក្យសុំចាត់ចែងរក្សាការពាររដ្ឋប្បវេណី ក្រោយពេលសាលក្រមសម្រេចអង្គសេចក្តីបានចូលជាស្ថាពរ

6 បើសិនជា មិនមានការគោរពអំឡុងពេលប្តឹងឧបាស្រ័យទេ

2 បើសិនជាមានការទាមទារបន្ថែម ក្រោយពេលដាក់ពាក្យបណ្ដឹង

# ករណីសិក្សារួម



ដី L

កម្មសិទ្ធិករ : Y

ឈ្មោះក្នុងគោលបញ្ជីដីធ្លី : Y



អ្នកឯងត្រូវចុះបញ្ជីផ្ទេរកម្មសិទ្ធិ
ដី L មកឱ្យខ្ញុំ !
(ដាក់ពាក្យបណ្ដឹង)



X → Y

ការទាមទារ : ទាមទារឱ្យចុះបញ្ជីផ្ទេរកម្មសិទ្ធិ
ដោយផ្អែកលើកិច្ចសន្យាលក់ទិញ

# ការបន្ថែម ឬ ការផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹង

<u>សភាពការណ៍បន្ថែមនៃ "ករណីសិក្សារួម"</u>

ពេលមុន Y បានបើករឺម៉កបុក X នៅពេល X ដើរ ហើយធ្វើឱ្យ X របួស។

ក្នុងកំឡុងពេលដែលរឿងក្តីនេះកំពុងត្រូវបានចាត់ការ X គិតថា ចង់ទាមទារបន្ថែមដូចតទៅ ៖

1) សំណងនៃការខូចខាតនៃថ្លៃព្យាបាលដោយសារគ្រោះថ្នាក់ចរាចរណ៍
2) សំណងនៃការខូចខាតដោយសារការយឺតយ៉ាវនៃការចុះបញ្ជីផ្ទេរកម្មសិទ្ធិ

# ករណីសិក្សារួម(អនុវត្ត)









ទាមទារសំណងនៃការខូចខាតនៃគ្រោះថ្នាក់ចរាចរណ៍

ទាមទារសំណងនៃការខូចខាតដោយសារការយឺតយ៉ាវនៃការចុះបញ្ជីផ្ទេរកម្មសិទ្ធិ

X

Y



ទាមទារនូវការចុះបញ្ជីផ្ទេរកម្មសិទ្ធិដោយផ្អែកលើការលក់ទិញ

# ការរួមបញ្ចូលនូវការទាមទារ

តើ X ត្រូវធ្វើនីតិវិធីយ៉ាងដូចម្តេចដែរ ?

តាមធម្មតា X អាចទាមទារច្រើនចំណុចចំពោះ Y នៅក្នុងនីតិវិធីនៃបណ្តឹងតែមួយបាន។

គេហៅថា "ការបញ្ចូលការទាមទារច្រើនចំណុចទៅក្នុងបណ្តឹងតែមួយ" (មាត្រា77)។



# ការបញ្ចូលការទាមទារច្រើនចំណុចទៅក្នុងបណ្តឹងតែមួយ

បើសិនជាសរសេរនូវការទាមទារច្រើនចំណុចនៅក្នុងពាក្យបណ្តឹងទៅ ការទាមទារច្រើនចំណុចនោះនឹងត្រូវបានបញ្ចូលតាំងពីពេលដាក់ពាក្យបណ្តឹង។

## ពាក្យបណ្តឹង

"ខ្លឹមសារនៃសាលក្រមដែលទាមទារ"

1 បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់១ម៉ឺនដុល្លារអាមេរិកទៅឱ្យដើមចោទ។

2 បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់២ម៉ឺនដុល្លារអាមេរិកទៅឱ្យដើមចោទ។

3 បង្គាប់ឱ្យចុងចម្លើយរើចេញ ហើយប្រគល់អាគារដែលមានចុះក្នុងបញ្ជីឧបសម្ព័ន្ធស្តីពីអចលនវត្ថុ ទៅឱ្យដើមចោទ។

# ការបន្ថែម ឬ ការផ្លាស់ប្ដូរនូវកម្មវត្ថុនៃបណ្ដឹង

តាមរយៈ "ការបន្ថែម ឬ ការផ្លាស់ប្ដូរនូវកម្មវត្ថុនៃបណ្ដឹង" គេអាចរួមបញ្ចូលនូវការទាមទារទៅក្នុងរឿងក្ដីដែលតុលាការកំពុងចាត់ការបាន។



# ការបន្ថែម ឬ ការផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹង

"ប្រភេទ"

1) ការបន្ថែមនូវការទាមទារ : "ការផ្លាស់ប្តូរដោយបន្ថែមនូវកម្មវត្ថុនៃបណ្តឹង"

2) ការប្តូរនូវការទាមទារ : "ការផ្លាស់ប្តូរដោយប្តូរកម្មវត្ថុនៃបណ្តឹង"
→ នេះមានរួមទាំងការដកនូវការទាមទារដែលបានធ្វើពីដំបូង

ហេតុនេះ ក្រោយការដោះសាតបរបស់ចុងចម្លើយ ចាំបាច់ត្រូវមានការយល់ព្រមពីចុងចម្លើយ(មាត្រា217 កថាខ័ណ្ឌទី1 និងទី2)

---

មាត្រា84 កថាខ័ណ្ឌទី1 វាក្យខ័ណ្ឌទី1
ដើមចោទអាចបន្ថែម ឬ ផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹង រហូតដល់ពេលចប់ការទាញហេតុផលដោយផ្ទាល់មាត់បាន លុះត្រាតែមិនមានការប្តូរមូលដ្ឋាននៃការទាមទារ។

# ការបន្ថែម ឬ ការផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹង

"ការបន្ថែមនូវកម្មវត្ថុនៃបណ្តឹង"



# ការបន្ថែម ឬ ការផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹង

“ការផ្លាស់ប្តូរដោយប្តូរនូវកម្មវត្ថុនៃបណ្តឹង”



# ការបន្ថែម ឬ ការផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹង

<u>ករណីដែលមិនបន្ថែមនូវការទាមទារទេ តែបង្កើនទឹកប្រាក់នៃការទាមទារ</u>

→ បន្ថែម ឬ ផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹង

(ឧ.)

ករណីដែលបានបង្កើនទឹកប្រាក់នៃការទាមទារសំណងនៃការខូចខាតដោយសារគ្រោះថ្នាក់ចរាចរណ៍ពី១ម៉ឺនដុល្លារអាមេរិក ទៅ២ម៉ឺនដុល្លារអាមេរិក

<u>ករណីបន្ថយទឹកប្រាក់នៃការទាមទារ</u>

→ការដកពាក្យបណ្តឹង(ការដកពាក្យបណ្តឹងមួយផ្នែក)

( ឧ. )

ករណីដែលបានបន្ថយទឹកប្រាក់នៃការទាមទារសំណងនៃការខូចខាតដោយសារគ្រោះថ្នាក់ចរាចរណ៍ពី២ម៉ឺនដុល្លារអាមេរិក មក១ម៉ឺនដុល្លារអាមេរិក

# ការដកពាក្យបណ្ដឹង(ឯកសារយោង)



# ការដកពាក្យបណ្តឹង(ឯកសារយោង)

ការដកពាក្យបណ្តឹង(មាត្រា217 កថាខ័ណ្ឌទី1) គឺជាការដកនូវការទាមទារទាំងអស់ ឬមួយផ្នែក។

ពេលដែលមានការដកពាក្យបណ្តឹង ត្រូវចាត់ទុកថា តុលាការមិនបានចាត់ការតាំងពីដំបូង( មាត្រា218 កថាខ័ណ្ឌទី1)។

ករណីចុងចម្លើយបានឆ្លើយតប ហើយចុងចម្លើយបានទទួលនូវផលប្រយោជន៍ពីសាលក្រមច្រានចោលនូវការទាមទារ ហេតុនេះ ការដកពាក្យបណ្តឹង ចាំបាច់ត្រូវមានការយល់ព្រមពីចុងចម្លើយ ( មាត្រា217 កថាខ័ណ្ឌទី2)។

# ករណីសិក្សារួម (អនុវត្ត)









X

ទាមទារសំណងនៃការខូចខាតនៃគ្រោះថ្នាក់ចរាចរណ៍ (បន្ថែម)

ទាមទារសំណងនៃការខូចខាតដោយសារការយឺតយ៉ាវនៃការចុះបញ្ជីផ្ទេរកម្មសិទ្ធិ (បន្ថែម)

ទាមទារនូវការចុះបញ្ជីផ្ទេរកម្មសិទ្ធិដោយផ្អែកលើកិច្ចសន្យាលក់ទិញ



Y

# ករណីសិក្សារួម(អនុវត្ត)

ករណីនេះគឺជាបញ្ហា"ផ្លាស់ប្តូរដោយបន្ថែមនូវកម្មវត្ថុនៃបណ្តឹង"។

អាចបន្ថែម ឬប្តូរនូវកម្មវត្ថុនៃបណ្តឹងបាន លុះត្រាតែមិនមានការប្តូរ "មូលដ្ឋាននៃការទាមទារ"(មាត្រា84 កថាខ័ណ្ឌទី1)។

X បានពិចារណាអំពីការបន្ថែមនូវការទាមទារដូចតទៅ៖
1.ទាមទារសំណងនៃការខូចខាតដោយសារគ្រោះថ្នាក់ចរាចរណ៍
2.ទាមទារសំណងនៃការខូចខាតដោយសារការយឺតយ៉ាវនៃការចុះបញ្ជីផ្ទេរកម្មសិទ្ធិ

# ករណីសិក្សារួម(អនុវត្ត)

អាចទទួលស្គាល់បានថា ពុំមានការប្តូរនូវ "មូលដ្ឋាននៃការទាមទារ" ក្នុងករណីដែលស្របនឹងល័ក្ខខ័ណ្ឌខាងក្រោមនេះ ៖

ការទាមទារទាំង២នេះ
① កើតមានឡើងពីវិវាទតែមួយ ឬពីវិវាទជាប់ៗគ្នា , ព្រមទាំង
② មានចំណុចវិវាទសំខាន់ៗរួមគ្នា។

ស្តីពីការផ្លាស់ប្តូរនូវកម្មវត្ថុនៃការទាមទារដែល X កំពុងគិតនេះ អាចចាត់ទុកថា ពុំមានប្តូរ "មូលដ្ឋាននៃការទាមទារ" ដែរ ឬទេ?

# ករណីសិក្សារួម(អនុវត្ត)

ការទាមទារទាំង២នេះ
① កើតមានឡើងពីវិវាទតែមួយ ឬពីវិវាទជាប់ៗគ្នា , ព្រមទាំង
② មានចំណុចវិវាទសំខាន់ៗរួមគ្នា។

1) ការទាមទារសំណងនៃការខូចខាតដោយសារគ្រោះថ្នាក់ចរាចរណ៍
- គ្មានពាក់ព័ន្ធទាល់តែសោះនឹងវិវាទដីធ្លី L។
  →មិនស្របនឹងល័ក្ខខ័ណ្ឌ①។
  →មិនអាចនិយាយថា គ្មានការប្តូរ "មូលដ្ឋាននៃការទាមទារ" បានទេ។

មិនអាចបន្ថែម ឬ ផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹងបានទេ។
X ត្រូវដាក់ពាក្យបណ្តឹងមួយផ្សេងទៀត។

# ករណីសិក្សារួម(អនុវត្ត)

ការទាមទារទាំង២នេះ
① កើតមានឡើងពីវិវាទតែមួយ ឬពីវិវាទជាប់ៗគ្នា , ព្រមទាំង
② មានចំណុចវិវាទសំខាន់ៗរួមគ្នា។

2) ការទាមទារសំណងនៃការខូចខាតដោយសារការយឺតយ៉ាវនៃការចុះបញ្ជីផ្ទេរកម្មសិទ្ធិ

- កើតមានឡើងពីវិវាទតែមួយជុំវិញរឿងដីធ្លី L។
- ចំណុចវិវាទសំខាន់ៗមានរួមគ្នានឹងការចុះបញ្ជីផ្ទេរកម្មសិទ្ធិ។

→ស្របនឹងល័ក្ខខ័ណ្ឌ①និង②។

→អាចនិយាយថា គ្មានការប្តូរនូវ "មូលដ្ឋាននៃការទាមទារ" ទេ។

អាចបន្ថែម ឬ ផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹងបាន

# បើសិនជាជួបករណីដូចខាងក្រោមនេះ តើត្រូវធ្វើដូចម្តេច ?

1 បើសិនជាពាក្យបណ្តឹងមានចំណុចខ្វះ

2 បើសិនជាមានការទាមទារបន្ថែម ក្រោយពេលដាក់ពាក្យបណ្តឹង

*3 បើសិនជាខ្លឹមសារនៃការទាមទាររបស់ដើមចោទនៅក្នុងពាក្យបណ្តឹង សរសេរមិនបានត្រឹមត្រូវ*

4 បើសិនជាមានការប្តឹងជាន់គ្នា ចំពោះរឿងក្តីតែមួយ

5 បើសិនជាមានការដាក់ពាក្យសុំចាត់ចែងរក្សាការពាររដ្ឋប្បវេណី ក្រោយពេលសាលក្រមសម្រេចអង្គសេចក្តីបានចូលជាស្ថាពរ

6 បើសិនជា មិនមានការគោរពអំឡុងពេលប្តឹងឧបាស្រ័យទេ

3 បើសិនជាខ្លឹមសារនៃការទាមទាររបស់ដើមចោទ នៅក្នុងពាក្យបណ្តឹង សរសេរមិនបានត្រឹមត្រូវ

# ករណីសិក្សារួម



ដី L

កម្មសិទ្ធិករ :Y

ឈ្មោះក្នុងគោលបញ្ជីដីធ្លី :Y

អ្នកឯងត្រូវចុះបញ្ជីផ្ទេរកម្មសិទ្ធិដី L មកឱ្យខ្ញុំ !
(ដាក់ពាក្យបណ្តឹង)





X → Y

ការទាមទារ : ទាមទារឱ្យចុះបញ្ជីផ្ទេរកម្មសិទ្ធិដោយផ្អែកលើកិច្ចសន្យាលក់ទិញ

# ខ្លឹមសារនៃការទាមទារដែលដើមចោទចង់បាន

<u>សភាពការណ៍បន្ថែមនៃ "ករណីសិក្សារួម"</u>

Y បានចុះបញ្ជីផ្ទេរកម្មសិទ្ធិដី L ដាក់ឈ្មោះ Y ដោយមិនឱ្យ X ដឹង ហើយក៏បានកាន់កាប់ដី L នោះទៅ។

X ចង់យកដីL ដែលជាកម្មសិទ្ធិរបស់គាត់មកវិញ។

នៅក្នុងបណ្ដឹងនេះ X គិតថា នឹងទាមទារដូចតទៅ ៖

1) ចុះបញ្ជីលុបចោលនូវការចុះបញ្ជីដោយផ្អែកលើកម្មសិទ្ធិ

2) ប្រគល់ដីមកវិញដោយផ្អែកលើកម្មសិទ្ធិ

# ករណីសិក្សារួម (អនុវត្ត)







ទាមទារឱ្យប្រគល់ដីដោយផ្អែកលើកម្មសិទ្ធិ

X

Y

ទាមទារឱ្យលុបចោលនូវការចុះបញ្ជីដោយផ្អែកលើកម្មសិទ្ធិ

# ខ្លឹមសារនៃការទាមទារដែលដើមចោទចង់បាន

ក្នុងករណីនេះ ដើមចោទទាមទារពីរចំណុចដូចតទៅ៖

1) ទាមទារឱ្យប្រគល់ដីដោយផ្អែកលើកម្មសិទ្ធិ
2) ទាមទារឱ្យលុបចោលនូវការចុះបញ្ជីដោយផ្អែកលើកម្មសិទ្ធិ

ទាំងនេះគឺជាការទាមទាររបស់ដើមចោទ ឱ្យគេប្រគល់ដី L និងការចុះបញ្ជីលុបចោលនូវការចុះបញ្ជីផ្ទេរកម្មសិទ្ធិ។
បណ្តឹងប្រភេទនេះ គេហៅថា "បណ្តឹងទាមទារតាវកាលិក"។

# ខ្លឹមសារនៃការទាមទារដែលដើមចោទចង់បាន

បើសិនជាបង្ហាញឱ្យបានត្រឹមត្រូវនូវខ្លឹមសារនៃការទាមទារដែលដើមចោទចង់បានទៅ នៅក្នុង"ខ្លឹមសារនៃសាលក្រមដែលទាមទារ"នៃពាក្យបណ្ដឹង ត្រូវសរសេរដូចតទៅ ៖

○

**ពាក្យបណ្ដឹង**

【សាលក្រមដែលទាមទារ】

1 បង្គាប់ឱ្យចុងចម្លើយប្រគល់ដីដែលមានចុះក្នុងបញ្ជីឧបសម្ព័ន្ធស្ដីពីអចលនវត្ថុ ទៅឱ្យដើមចោទ។

2 បង្គាប់ឱ្យចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីលុបចោលនូវការចុះបញ្ជីផ្ទេរកម្មសិទ្ធិដែលមានចុះក្នុងបញ្ជីឧបសម្ព័ន្ធស្ដីពីការចុះបញ្ជី ពាក់ព័ន្ធនឹងដីដែលមានចុះក្នុងបញ្ជីឧបសម្ព័ន្ធស្ដីពីអចលនវត្ថុ។

# ខ្លឹមសារនៃការទាមទារដែលដើមចោទចង់បាន

មានភាគីខ្លះមិនសូវមានចំណេះដឹងអំពីច្បាប់ទេ ម្ល៉ោះហើយ គាត់មិនអាចសរសេរឱ្យត្រឹមត្រូវបានទេ គាត់សរសេរដូចខាងក្រោមនេះ ក៏មិនដឹង៖

**ពាក្យបណ្ដឹង**

【ខ្លឹមសារនៃសាលក្រមដែលទាមទារ】

ដីដែលមានចុះក្នុងបញ្ជីឧបសម្ព័ន្ធស្ដីពីអចលនវត្ថុ គឺជាដីរបស់ដើមចោទ។

នេះគឺជាការទាមទារដើម្បីបញ្ជាក់ថា ដើមចោទជាម្ចាស់កម្មសិទ្ធិលើដី L ។

បណ្ដឹងប្រភេទនេះ គេហៅថា "បណ្ដឹងបញ្ជាក់"។

# ខ្លឹមសារនៃការទាមទារដែលដើមចោទចង់បាន

បើសិនជាយល់ឃើញថា ការទាមទាររបស់ដើមចោទមានហេតុផលត្រឹមត្រូវ តុលាការនឹងចេញសាលក្រមដូចតទៅ ៖

**សាលក្រម**

【សេចក្តីសម្រេចបញ្ចប់】

បញ្ជាក់ថា ដើមចោទមានកម្មសិទ្ធិលើដីដែលមានចុះក្នុងបញ្ជីឧបសម្ព័ន្ធស្តីពីអចលនវត្ថុ។

សាលក្រមបែបនេះ គេហៅថា "សាលក្រមបញ្ជាក់"។

ក៏ប៉ុន្តែ

# ខ្លឹមសារនៃការទាមទារដែលដើមចោទចង់បាន

តុលាការមិនអាចចេញសាលក្រមដូចខាងក្រោមនេះ តាមទំនើងចិត្តរបស់ខ្លួនបានឡើយ (មាត្រា182 កថាខណ្ឌទី2)។

## សាលក្រម

【សេចក្តីសម្រេចបញ្ចប់】

1 បង្គាប់ឱ្យចុងចម្លើយប្រគល់ដីដែលមានចុះក្នុងបញ្ជីឧបសម្ព័ន្ធស្តីពីអចលនវត្ថុ ទៅឱ្យដើមចោទ។

2 បង្គាប់ឱ្យចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីលុបចោលនូវការចុះបញ្ជីផ្ទេរកម្មសិទ្ធិដែលមានចុះក្នុងបញ្ជីឧបសម្ព័ន្ធស្តីពីការចុះបញ្ជី ពាក់ព័ន្ធនឹងដីដែលមានចុះក្នុងបញ្ជីឧបសម្ព័ន្ធស្តីពីអចលនវត្ថុ។

មាត្រា 182 កថាខណ្ឌទី2

តុលាការមិនអាចចេញសាលក្រមចំពោះចំណុចណាដែលភាគីមិនបានសុំឡើយ។

# ខ្លឹមសារនៃការទាមទារដែលដើមចោទចង់បាន

បើអីចឹង  តើ "សាលក្រមបញ្ជាក់" អំបាញ់មិញ មានបញ្ហាឬទេ ?

## សាលក្រម

【សេចក្តីសម្រេចបញ្ចប់】

បញ្ជាក់ថា ដើមចោទមានកម្មសិទ្ធិលើដីដែលមានចុះក្នុងបញ្ជីឧបសម្ព័ន្ធស្តីពីអចលនវត្ថុ។

? ?

# ខ្លឹមសារនៃការទាមទារដែលដើមចោទចង់បាន

នៅក្នុង"សាលក្រមបញ្ជាក់"អំបាញ់មិញ មានបញ្ហាដូចខាងក្រោមនេះ ម្ល៉ោះហើយ ខ្លឹមសារនៃការទាមទារដែលដើមចោទចង់បាន មិនអាចសម្រេចបានឡើយ។

*Oh, No!*



X

តាមរយៈសាលក្រមបញ្ជាក់ គេមិនអាច "អនុវត្តដោយបង្ខំឱ្យប្រគល់ដីវិញ"បានទេ។



អាជ្ញាសាលា

តាមរយៈសាលក្រមបញ្ជាក់ គេមិនអាច "ចុះបញ្ជីលុបចោលនូវការចុះបញ្ជី"បានទេ។



មន្ត្រីចុះបញ្ជី

# ខ្លឹមសារនៃការទាមទារដែលដើមចោទចង់បាន

ដើម្បីសម្រេចនូវខ្លឹមសារនៃការទាមទារដែលដើមចោទចង់បាន គាត់ត្រូវដាក់ពាក្យបណ្ដឹងទាមទារដូចតទៅម្ដងទៀតទៅសាលាដំបូង ៖

1) ការប្រគល់ដី

2) ការចុះបញ្ជីលុបនូវការចុះបញ្ជីផ្ទេរកម្មសិទ្ធិ

ក៏ប៉ុន្តែខ្លឹមសារនៃការជំនុំជម្រះនៃបណ្ដឹងនេះ ដូចគ្នានឹងការជំនុំជម្រះនៃបណ្ដឹងមុនដែរ។



# ខ្លឹមសារនៃការទាមទារដែលដើមចោទចង់បាន

ម្ល៉ោះហើយ

## គុណវិបត្តិ

- ការងាររបស់តុលាការក៏កើន។ ការចំណាយថវិកាបានមកពន្ធក៏ច្រើន។
- ចំពោះដើមចោទក៏ដោយ ចុងចម្លើយក៏ដោយ ការឡើងតុលាការដោយសារតែរឿងដដែល គឺជាបន្ទុកដែលគ្មានប្រយោជន៍សម្រាប់គេ។
- ជំនឿរបស់ប្រជាពលរដ្ឋ ទៅលើមុខងារដោះស្រាយវិវាទរបស់តុលាការ នឹងបាត់បង់។

ជាដើម។

ដើម្បីចៀសវាងនូវបញ្ហាបែបនេះ តើត្រូវធ្វើយ៉ាងដូចម្តេចដែរ ?

# ពាក្យបណ្ដឹង

[ខ្លឹមសារនៃសាលក្រមដែលទាមទារ]

ដីដែលមានចុះក្នុងបញ្ជីឧបសម្ព័ន្ធស្ដីពីអចលនវត្ថុ គឺជាដីរបស់ដើមចោទ។

បើសិនជាអានចំណុចស្ដីពី "ខ្លឹមសារនៃសាលក្រមដែលទាមទារ" ទៅឃើញថា ដើមចោទទាមទារឱ្យតុលាការបញ្ជាក់អំពីកម្មសិទ្ធិ ក៏ប៉ុន្តែបើសិនជាអានពាក្យបណ្ដឹងទាំងមូលទៅឃើញថា គាត់ដូចជាទាមទារចំពោះចុងចម្លើយ ឱ្យប្រគល់ដីមកវិញ និងឱ្យចុះបញ្ជីលុបចោលនូវការចុះបញ្ជីផ្ទេរកម្មសិទ្ធិ។

ក្នុងករណីនេះ  តើចៅក្រមត្រូវធ្វើយ៉ាងដូចម្ដេច ?



# ពាក្យបណ្ដឹង

[ខ្លឹមសារនៃសាលក្រមដែលទាមទារ]

ដីដែលមានចុះក្នុងបញ្ជីឧបសម្ព័ន្ធស្ដីពីអចលនវត្ថុ គឺជាដីរបស់ដើមចោទ។

តើអ្នកបានដាក់ពាក្យបណ្ដឹងដោយចង់បានអ្វីដែរ ?

តើចង់បញ្ជាក់អំពីកម្មសិទ្ធិលើដី L មែនឬទេ ?



X



△

# ពាក្យបណ្ដឹង

[ខ្លឹមសារនៃសាលក្រមដែលទាមទារ]

ដីដែលមានចុះក្នុងបញ្ជីឧបសម្ព័ន្ធស្ដីពីអចលនវត្ថុ គឺជាដីរបស់ដើមចោទ។

ទេ  មិនមែនទេ!
ដី L នោះ គឺជារបស់ខ្ញុំ។
ហេតុនេះហើយ ខ្ញុំចង់ឱ្យចុងចម្លើយសងមកខ្ញុំវិញភ្លាម។
លើសពីនេះ  ខ្ញុំចង់ឱ្យគាត់កាត់ឈ្មោះមកឱ្យខ្ញុំវិញ។



X



# ពាក្យបណ្តឹង

[ខ្លឹមសារនៃសាលក្រមដែលទាមទារ]

ដីដែលមានចុះក្នុងបញ្ជីឧបសម្ព័ន្ធស្ដីពីអចលនវត្ថុ គឺជាដីរបស់ដើមចោទ។

ប៉ុន្តែនៅក្នុងពាក្យបណ្តឹងរបស់អ្នក ខ្លឹមសារដែលទាមទារ គឺការបញ្ជាក់អំពីកម្មសិទ្ធលើដី L នោះទេតើ!

ប្រសិនជាអ្នកចង់ឱ្យគេប្រគល់ដីមកវិញ ហើយចុះបញ្ជីលុបចោលនូវការចុះបញ្ជីផ្ទេរកម្មសិទ្ធិ ត្រូវប្តូរខ្លឹមសារទៅតាមអ្វីដែលអ្នកបាននិយាយអំបាញ់មិញ។



X



# ពាក្យបណ្តឹង

[ខ្លឹមសារនៃសាលក្រមដែលទាមទារ]

ដីដែលមានចុះក្នុងបញ្ជីឧបសម្ព័ន្ធស្តីពីអចលនវត្ថុ គឺជាដីរបស់ដើមចោទ។

ចាំ ! ខ្ញុំយល់ហើយ ។
ខ្ញុំនឹងប្តូរទៅតាមហ្នឹង។



X



# ការបំភ្លឺ

ការសួរ ឬការបញ្ជាក់ចំពោះភាគី ស្តីពីការទាមទារ ការអះអាង ឬភស្តុតាងជាអាទ៍ របស់តុលាការបែបនេះ គេហៅថា "ការបំភ្លឺ"។



X



# ការបំភ្លឺ

ក្នុងបណ្ដឹង

- តើភាគីទាមទារអ្វីខ្លះ
- តើភាគីអះអាងអ្វីខ្លះ
- តើភាគីដាក់ភស្តុតាងអ្វីខ្លះ

ជាដើម គឺត្រូវប្រគល់ទៅឱ្យភាគីជាអ្នកសម្រេច។ ក៏ប៉ុន្តែ បើសិនជាតុលាការប្រគល់ទាំងស្រុងបែបនេះទៅ មានពេលខ្លះ អាចមានលទ្ធផលអយុត្តិធម៌ទៅវិញក៏មានដែរ។ ក្នុងករណីបែបនេះ តុលាការត្រូវធ្វើការ “បំភ្លឺ”។

---

មាត្រា 90 កថាខ័ណ្ឌទី1

ដើម្បីឱ្យចំណុចនៃអង្គហេតុ និង អង្គច្បាប់ដែលទាក់ទងនឹងបណ្ដឹង មានភាពច្បាស់លាស់ តុលាការអាចសាកសួរភាគី ឬ ឱ្យភាគីអះអាង ឬ បញ្ជាក់ភស្តុតាង ចំពោះចំណុចនោះ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ ការទាញហេតុផលដោយផ្ទាល់មាត់បាន ។

# ការបំភ្លឺ

“ប្រភេទ”

- ការបំភ្លឺដោយអវិជ្ជមាន
  គឺជាការបំភ្លឺនៃករណីសួរសំណួរពាក់ព័ន្ធនឹងការអះអាងជាដើម ដែលមិនច្បាស់លាស់របស់ភាគី ដើម្បីបញ្ជាក់ឱ្យបានច្បាស់លាស់អំពីខ្លឹមសារនោះ។

- ការបំភ្លឺដោយវិជ្ជមាន
  គឺជាការបំភ្លឺនៃករណីដែលតុលាការសួរណែនាំឱ្យភាគីធ្វើការអះអាងសមស្របថ្មី ឬដាក់ភស្តុតាងថ្មី។

បន្ទាប់មក សូមពិចារណាលំអិត។

# ករណីសិក្សារួម



ដី L

កម្មសិទ្ធិករ : Y

ឈ្មោះក្នុងគោលបញ្ជីដីធ្លី : Y

នៅថ្ងៃទី1 មករា 2016  ខ្ញុំបាន ទិញដី L ពី Y ក្នុងតម្លៃ១ម៉ឺន ដុល្លារអាមេរិក។





X

Y

Y មិនព្រមចុះបញ្ជីផ្ទេរកម្មសិទ្ធិដី L ទេ។

# ការបំភ្លឺ

## <u>ឧទាហរណ៍នៃការបំភ្លឺដោយអវិជ្ជមាន</u>

នៅក្នុងពាក្យបណ្ដឹង X បានអះអាងថា "នៅថ្ងៃទី1 ខែមករា ឆ្នាំ2016 ខ្ញុំបានបង់ថ្លៃលក់ទិញ ១ម៉ឺនដុល្លារអាមេរិក ជា<u>សាច់ប្រាក់</u>ទៅឱ្យ Y ហើយ"។ ក្រោយមក នៅក្នុងឯកសារត្រៀម X បានអះអាងថា "នៅថ្ងៃទី1 ខែមករា ឆ្នាំ 2016 ខ្ញុំបានបង់ថ្លៃលក់ទិញ ១ម៉ឺនដុល្លារអាមេរិកដោយ<u>ផ្ទេរតាមធនាគារ</u>ទៅឱ្យ Y ហើយ"។

ការបំភ្លឺ

"ស្ដីពីការអះអាងស្ដីពីការបង់ថ្លៃលក់ទិញ តើបានបង់ជាសាច់ប្រាក់ ឬផ្ទេរតាមធនាគារ?"

# ការបំភ្លឺ

## ឧទាហរណ៍នៃការបំភ្លឺដោយអវិជ្ជមាន

X បានអះអាងថា “នៅថ្ងៃទី1 ខែមករា ឆ្នាំ 2016 ខ្ញុំបានបង្កើតកិច្ចសន្យាលក់ទិញនឹង Y ហើយបានបង្កើត ឯកសារ”។

ការបំភ្លឺ

“ស្ដីអំពីឯកសារនោះ តើជាឯកសារដូចម្ដេចដែរ សូមបញ្ជាក់ឱ្យបានច្បាស់លាស់។”

# ការបំភ្លឺ

## ឧទាហរណ៍នៃការបំភ្លឺដោយអវិជ្ជមាន

Y បានអះអាងថា “ខ្ញុំបានបង្កើតកិច្ចសន្យាលក់ទិញ ដោយសារគេបោកខ្ញុំ”។

ការបំភ្លឺ

“ដូច្នេះ មានន័យថា អ្នកទទួលស្គាល់នូវការបង្កើតកិច្ចសន្យាលក់ទិញនោះមែនឬទេ?” (※)។ បើសិនជាអ្នកអះអាងថា ជាការឆបោក (ក្រមរដ្ឋប្បវេណី មាត្រា345 កថាខ័ណ្ឌទី2) សូមអះអាងឱ្យបានលំអិត។”

(※)តាមរយៈការទទួលស្គាល់នេះ គឺ Y បានសារភាព។ ដូច្នេះភាគីម្ខាងទៀត មិនចាំបាច់ធ្វើការបញ្ជាក់ភស្តុតាងទេ(មាត្រា123 កថាខ័ណ្ឌទី2)។

# ការបំភ្លឺ

## ឧទាហរណ៍នៃការបំភ្លឺដោយវិជ្ជមាន

X មិនបានដាក់ឯកសារអ្វីសោះពាក់ព័ន្ធនឹងការបង្កើតកិច្ចសន្យាលក់ទិញ។

ការបំភ្លឺ

“តើគ្មានលិខិតនៃកិច្ចសន្យាពាក់ព័ន្ធនឹងការលក់ទិញ ឬយ៉ាងណាដែរ? បើសិនជាមាន សូមដាក់មកតុលាការ។”

# ការបំភ្លឺ

<u>ឧទាហរណ៍នៃការបំភ្លឺដោយវិជ្ជមាន</u>

X មិនបានអះអាងអំពីការបង្កើតលិខិតយថាភូតពាក់ព័ន្ធនឹងកិច្ចសន្យាលក់ទិញទេ (ក្រមរដ្ឋប្បវេណី មាត្រា336 កថាខ័ណ្ឌទី2)។(※)

ការបំភ្លឺ

“សូមធ្វើការអះអាងអំពីការបង្កើតលិខិតយថាភូត”។

(※)ខ្វះ “អង្គហេតុដែលជាមូលហេតុនៃការទាមទារ” (មាត្រា75 កថាខ័ណ្ឌទី3)។

# ការបំភ្លឺ

## កន្លែងធ្វើការបំភ្លឺ

- កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល
- កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់
- ក្រៅពីកាលបរិច្ឆេទ

## វិធីធ្វើការបំភ្លឺ

- តាមមាត់
- តាមឯកសារ

# ការបំភ្លឺ

តើភាគីធ្វើការបំភ្លឺឬទេនោះ គឺត្រូវបានប្រគល់ឱ្យភាគីជាអ្នកសម្រេច។

បើសិនជា A ធ្វើការបំភ្លឺ គាត់នឹង "បន្ថែមនូវកម្មវត្ថុនៃបណ្ដឹង"។

ការដែលតុលាការធ្វើការបំភ្លឺ អាចកត់ត្រាទុកក្នុងកំណត់ហេតុនៃកាលបរិច្ឆេទបាន(មាត្រា111 ចំណុច ង., មាត្រា119 កថាខ័ណ្ឌទី1 ចំណុច ង.)។

- ដើម្បីកត់ត្រាទុកអំពីចំណាត់ការរបស់តុលាការ។

# ការបំភ្លឺ

នីតិវិធីនៃបណ្ដឹង គឺជាឯកទេស និង ជាបច្ចេកទេស។ ដោយសារតែភាគីមិនដឹងរបៀបសរសេរឯកសារជាដើម ហេតុនេះហើយបានជាមានចំណុចខ្លះមិនត្រឹមត្រូវ មិនច្បាស់លាស់។

ក្នុងករណីដែលតុលាការ រកឃើញចំណុចដែលសរសេរមិនត្រឹមត្រូវ ឬ មិនច្បាស់លាស់ គប្បីតែធ្វើការបញ្ជាក់ឱ្យច្បាស់លាស់តាមរយៈ "ការបំភ្លឺ"។

ជាពិសេស “ការបំភ្លឺ” ដែលធ្វើជ្រុលពេក នឹងធ្វើឱ្យភាគីម្ខាងទៀតមានអារម្មណ៍ថា អយុត្តិធម៌ ដូច្នេះ ត្រូវធ្វើការបំភ្លឺត្រឹមកម្រិតមួយដែលសមស្របប៉ុណ្ណោះ។

# “រូបភាពពន្យល់អំពីការប្រើ ឬ មិនប្រើសិទ្ធិបំភ្លឺ”



# បើសិនជាជួបករណីដូចខាងក្រោមនេះ  តើត្រូវធ្វើដូចម្តេច ?

1  បើសិនជាពាក្យបណ្តឹងមានចំណុចខ្វះ

2  បើសិនជាមានការទាមទារបន្ថែម ក្រោយពេលដាក់ពាក្យបណ្តឹង

3  បើសិនជាខ្លឹមសារនៃការទាមទាររបស់ដើមចោទនៅក្នុងពាក្យបណ្តឹង សរសេរមិនបានត្រឹមត្រូវ

*4  បើសិនជាមានការប្តឹងជាន់គ្នា ចំពោះរឿងក្តីតែមួយ*

5  បើសិនជាមានការដាក់ពាក្យសុំចាត់ចែងរក្សាការពាររដ្ឋប្បវេណី ក្រោយពេលសាលក្រមសម្រេចអង្គសេចក្តីបានចូលជាស្ថាពរ

6  បើសិនជា មិនមានការគោរពអំឡុងពេលប្តឹងឧបាស្រ័យទេ

4 បើសិនជាមានការប្តឹងជាន់គ្នា
ចំពោះរឿងក្តីតែមួយ

# ករណីសិក្សារួម



ដី L

កម្មសិទ្ធិករ:Y

ឈ្មោះក្នុងគោលបញ្ជីដីធ្លី:Y

អ្នកឯងត្រូវចុះបញ្ជីផ្ទេរកម្មសិទ្ធិ
ដីL មកឱ្យខ្ញុំ !
(ដាក់ពាក្យបណ្ដឹង)





X → Y

ការទាមទារ : ការទាមទារឱ្យចុះបញ្ជីផ្ទេរកម្មសិទ្ធិ
ដោយផ្អែកលើកិច្ចសន្យាលក់ទិញ

# បណ្តឹងជាន់គ្នា

## សភាពការណ៍បន្ថែមនៃ "ករណីសិក្សារួម"

X បានដាក់ពាក្យបណ្តឹងទៅសាលាដំបូង A។

- សាលាដំបូង A មានសមត្ថកិច្ចជម្រះក្តីនៅទីកន្លែងដែលមានលំនៅដ្ឋានរបស់Y (មាត្រា8 ចំណុច ក.)។

X មានអារម្មណ៍ថា ប្រហែលជាចាញ់ក្តីដែលបានដាក់នៅសាលាដំបូង A។

ម្ល៉ោះហើយ X ក៏បានដាក់ពាក្យបណ្តឹងដែលមានខ្លឹមសារដូចគ្នាទៅសាលាដំបូង B ។

- សាលាដំបូង B មានសមត្ថកិច្ចជម្រះក្តីនៅទីកន្លែងដែលមានទីតាំងនៃដី L(មាត្រា9 ចំណុច ឆ.)។

# ករណីសិក្សារួម (បន្ថែម)



① សាលាដំបូង A



② សាលាដំបូង B




ការទាមទារឱ្យចុះបញ្ជីផ្ទេរកម្មសិទ្ធិដោយ
ផ្អែកលើកិច្ចសន្យាលក់ទិញ

# បណ្ដឹងជាន់គ្នា

បណ្ដឹងរបស់ X បែបនេះ គេហៅថា "បណ្ដឹងជាន់គ្នា"។

បណ្ដឹងជាន់គ្នា

នេះគឺជាការដាក់ពាក្យបណ្ដឹងមួយផ្សេងទៀត ដែលមានខ្លឹមសារដូចគ្នានឹងរឿងក្ដីដែលតុលាការកំពុងចាត់ការ។

※ការដាក់ពាក្យបណ្ដឹងក្រោយសាលក្រមចូលជាស្ថាពរគឺជាបញ្ហាមួយផ្សេងទៀត។

ស្ដីពីបណ្ដឹងជាន់គ្នា តើមានបញ្ហាអ្វីខ្លះដែរ ?

---

មាត្រា 83

ចំពោះរឿងក្ដីដែលតុលាការកំពុងចាត់ការ ភាគីមិនអាចប្ដឹងទៀតបានឡើយ ។

# បណ្ដឹងជាន់គ្នា

"បញ្ហាដែលមាន"

- Y ត្រូវឆ្លើយតបចំពោះរឿងក្ដីដដែលច្រើនដង។
  តាមធម្មតា Y ធ្វើការឆ្លើយតបតែម្ដងជាការគ្រប់គ្រាន់។
- តុលាការត្រូវចាត់ការរឿងក្ដីដដែលច្រើនដង។
  តាមធម្មតា តុលាការចាត់ការតែម្ដងជាការគ្រប់គ្រាន់។
- បើសិនជាបានទទួលនូវសាលក្រមដែលមានខ្លឹមសារខុសគ្នា នឹងធ្វើឱ្យមានការជ្រួលច្របល់។
  (ឧ.) សាលាដំបូង A : ទទួលស្គាល់នូវការទាមទារ
  សាលាដំបូង B : ច្រានចោលនូវការទាមទារ

# បណ្ដឹងជាន់គ្នា

ដោយសារមានបញ្ហាទាំងនេះហើយ បានជា “បណ្ដឹងជាន់គ្នា” ត្រូវបានហាម(មាត្រា83)។

ជាលទ្ធផលបណ្ដឹងដែលបានដាក់ក្រោយ គឺជាបណ្ដឹងខុសច្បាប់។

សាលាដំបូង B នឹងលើកបណ្ដឹងនេះចោល(មាត្រា81)។

# បណ្តឹងជាន់គ្នា

តើត្រូវវិនិច្ឆ័យយ៉ាងដូចម្តេច ទើបដឹងថាជាបណ្តឹង "បណ្តឹងជាន់គ្នា" ឬ មិនមែន?

ដើម្បីអាចចាត់ទុកថាជា "បណ្តឹងជាន់គ្នា" ត្រូវតែជារឿងក្តី "តែមួយ"។

តើជារឿងក្តី"តែមួយ"ឬទេនោះ ត្រូវវិនិច្ឆ័យអំពី

1) ភាគី

2) ការទាមទារ

# បណ្ដឹងជាន់គ្នា

តើបណ្ដឹងពីរខាងក្រោមនេះរបស់ X ជារឿងក្ដី"តែមួយ" ឬទេ ?

បណ្ដឹងទី១ (សាលាដំបូង A)

- X→Y "បង្គាប់ឱ្យចុះបញ្ជីផ្ទេរកម្មសិទ្ធិដី L"។
- ការទាមទារឱ្យចុះបញ្ជីផ្ទេរកម្មសិទ្ធិដោយផ្អែកលើកិច្ចសន្យាលក់ទិញដីធ្លីចុះថ្ងៃទី1 ខែមករា ឆ្នាំ2016

បណ្ដឹងទី២ (សាលាដំបូង B)

- X→Y "បង្គាប់ឱ្យចុះបញ្ជីផ្ទេរកម្មសិទ្ធិដី L"។
- ការទាមទារឱ្យចុះបញ្ជីផ្ទេរកម្មសិទ្ធិដោយផ្អែកលើកិច្ចសន្យាលក់ទិញដីធ្លីចុះថ្ងៃទី1 ខែមករា ឆ្នាំ2016

# បណ្ដឹងជាន់គ្នា

1) ភាគី:X, Y （ដូចគ្នា)

2) ការទាមទារ : ការទាមទារឱ្យចុះបញ្ជីផ្ទេរកម្មសិទ្ធិដោយផ្អែកលើកិច្ចសន្យាលក់ទិញដីធ្លីចុះថ្ងៃទី1 ខែមករា ឆ្នាំ2016 (ដូចគ្នា)

ភាគីក៏ដូចគ្នា ការទាមទារក៏ដូចគ្នា ដូច្នេះនេះគឺជាបណ្ដឹង "តែមួយ"។

# បណ្ដឹងជាន់គ្នា

បន្ទាប់មក សូមយកករណីសិក្សាមួយផ្សេងទៀត ដើម្បីពិចារណាមើលថា តើជារឿងក្ដី "តែមួយ" ឬ ទេ ?

# បណ្តឹងជាន់គ្នា

"ឧទាហរណ៍ទី១"

## បណ្តឹងទី១

- P→D "បង្គាប់ឱ្យរើចេញ ហើយប្រគល់ដី Mទៅឱ្យP។"
- ការទាមទារឱ្យប្រគល់ដីវិញដោយផ្អែកលើកម្មសិទ្ធិ

## បណ្តឹងទី២

- P→D "បង្គាប់ឱ្យរើចេញ ហើយប្រគល់ដីMទៅឱ្យP។"
- ការទាមទារឱ្យប្រគល់ដីវិញដោយផ្អែកលើកម្មសិទ្ធិ

# បណ្ដឹងជាន់គ្នា

1) ភាគី:P, D （ដូចគ្នា)

2) ការទាមទារ : ការទាមទារឱ្យប្រគល់ដីវិញដោយផ្អែកលើកម្មសិទ្ធិ （ដូចគ្នា)

នេះគឺជារឿងក្ដី “តែមួយ”។

# បណ្ដឹងជាន់គ្នា

"ឧទាហរណ៍ទី២"

បណ្ដឹងទី១

- P→D "បង្គាប់ឱ្យបង់ប្រាក់១ម៉ឺនដុល្លារអាមេរិក"
- ការទាមទារឱ្យបង់ប្រាក់ដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគចុះថ្ងៃទី1 ខែតុលា ឆ្នាំ2015

បណ្ដឹងទី២

- P→D "បង្គាប់ឱ្យបង់ប្រាក់១ម៉ឺនដុល្លារអាមេរិក"
- ការទាមទារឱ្យបង់ប្រាក់ដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគចុះថ្ងៃទី1 ខែមករា ឆ្នាំ2016

# បណ្តឹងជាន់គ្នា

1) ភាគី : P, D （ដូចគ្នា）

2) ការទាមទារ : ថ្ងៃខែនៃកិច្ចសន្យាផ្សេងគ្នា

នេះមិនមែនជារឿងក្តី"តែមួយ"ទេ។

# បណ្តឹងជាន់គ្នា

"ឧទាហរណ៍ទី៣"

បណ្តឹងទី១

- P→D "បង្គាប់ឱ្យបង់ប្រាក់១ម៉ឺនដុល្លារអាមេរិក"
- ការទាមទារឱ្យបង់ប្រាក់ដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគចុះថ្ងៃទី1 ខែតុលា ឆ្នាំ2015

បណ្តឹងទី២

- D → P "ពុំមានកាតព្វកិច្ចបង់ប្រាក់១ម៉ឺនដុល្លារអាមេរិកដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគចុះថ្ងៃទី1 ខែតុលា ឆ្នាំ2015ទេ។"
- ការបញ្ជាក់អំពីនត្ថិភាពនៃកិច្ចសន្យាខ្ចីបរិភោគចុះថ្ងៃទី1 ខែតុលា ឆ្នាំ2015

# បណ្ដឹងជាន់គ្នា

1) ភាគី : P, D (ដូចគ្នា)

2) ការទាមទារ : អត្ថិភាព ឬ នត្ថិភាពនៃកិច្ចសន្យាតែមួយ(ដូចគ្នា)

→មើលមួយភ្លែតទៅដូចជាផ្សេងគ្នា ក៏ប៉ុន្តែបណ្ដឹងណាមួយក៏ពាក់ព័ន្ធនឹងកិច្ចសន្យាខ្ចីបរិភោគនៅថ្ងៃទី1 ខែតុលា ឆ្នាំ 2015 ដែរ គឺមួយ "ស្ដីពីការទាមទារឱ្យបង់ប្រាក់ដោយផ្អែកលើអត្ថិភាពនៃកិច្ចសន្យានេះ" ហើយមួយទៀត "ស្ដីពីការបញ្ជាក់ដោយផ្អែកលើនត្ថិភាពនៃកិច្ចសន្យានេះ" ដូច្នេះ គឺជាវិវាទស្ដីពីអត្ថិភាព ឬ នត្ថិភាពនៃកិច្ចសន្យាតែមួយ។

នេះគឺជារឿងក្ដី "តែមួយ"។

# បណ្ដឹងជាន់គ្នា

"ឧទាហរណ៍ទី៩"

បណ្ដឹងទី១

- P→D "បង្គាប់ឱ្យរើចេញ ហើយប្រគល់ដី M ទៅឱ្យ P។"
- ទាមទារឱ្យប្រគល់វិញដោយផ្អែកលើកម្មសិទ្ធិ

បណ្ដឹងទី២

- P→E "បង្គាប់ឱ្យរើចេញ ហើយប្រគល់ដី M ទៅឱ្យ P។"
- ទាមទារឱ្យប្រគល់វិញដោយផ្អែកលើកម្មសិទ្ធិ

※ D និង E បានកាន់កាប់ដី M ដូចគ្នា។

# បណ្ដឹងជាន់គ្នា

1) ភាគី :P, D ／ P, E （ខុសគ្នា）

2) ការទាមទារ : ទាមទារឱ្យរើចេញ ហើយប្រគល់ទៅឱ្យ P ដោយផ្អែកលើកម្មសិទ្ធិ (ដូចគ្នា)

មិនមែនជារឿងក្ដី"តែមួយ"ទេ។

# បណ្ដឹងជាន់គ្នា

បើសិនជាសាលាដំបូង B មិនបានចាប់ភ្លឹកថាជាបណ្ដឹងជាន់គ្នា ហើយបានចេញសាលក្រម ហើយសាលក្រមបានចូលជាស្ថាពរ។ តើក្នុងករណីនេះ នឹងក្លាយទៅជាយ៉ាងដូចម្ដេចដែរ?

នេះគឺជាបញ្ហា "អាជ្ញាអស់ជំនុំនៃការវិនិច្ឆ័យ" (មាត្រា194)។

※ករណីដែលបានដាក់ពាក្យបណ្ដឹងម្ដងទៀត ក្រោយពេលសាលក្រមបានចូលជាស្ថាពរក៏ដូចគ្នាដែរ។

# បណ្ដឹងជាន់គ្នា

ដោយសារតែមិនបានចាប់ភ្លឹកថាជាបណ្ដឹងជាន់គ្នា ហើយសាលាដំបូងA និងB បានចេញសាលក្រម ហើយសាលក្រមបានចូលជាស្ថាពរទាំងអស់ដូចគ្នា។
លើសពីនេះទៀត ខ្លឹមសារនៃសាលក្រមទាំងពីរនេះខុសគ្នា។

សាលាដំបូង A : ទទួលស្គាល់នូវការទាមទារ

សាលាដំបូង B : ច្រានចោលនូវការទាមទារ

**ក្នុងករណីនេះ តើយ៉ាងណាដែរ?**

នេះជាមូលហេតុនៃការជំនុំជម្រះសាជាថ្មី(មាត្រា307 កថាខ័ណ្ឌទី1 ចំណុច ញ)។
លំអិតគឺ សាលក្រមរបស់តុលាការដែលបានចេញក្រោយ ត្រូវបានលុបចោល។

# ករណីសិក្សារួម



ដី L

កម្មសិទ្ធិករ:Y

ឈ្មោះក្នុងគោលបញ្ជីដីធ្លី:Y



អ្នកឯងត្រូវចុះបញ្ជីផ្ទេរកម្មសិទ្ធិដីL មកឱ្យខ្ញុំ !
(ដាក់ពាក្យបណ្ដឹង)



X → Y

ការទាមទារ : ការទាមទារឱ្យចុះបញ្ជីផ្ទេរកម្មសិទ្ធិដោយផ្អែកលើកិច្ចសន្យាលក់ទិញ

# ការដាក់ពាក្យបណ្ដឹងម្ដងទៀត ក្រោយពេលសាលក្រមចូលជាស្ថាពរ

<u>សភាពការណ៍បន្ថែមនៃ “ករណីសិក្សារួម”</u>

សាលក្រមដែលច្រានចោលនូវការទាមទាររបស់ X បានចូលជាស្ថាពរ។

X មិនស្របចិត្តនឹងខ្លឹមសារនៃសាលក្រមនេះក៏បានដាក់ពាក្យបណ្ដឹងដែលមានខ្លឹមសារដូចគ្នាម្ដងទៀតចំពោះ Y។

# ករណីសិក្សារួម(បន្ថែម)



ដី L

កម្មសិទ្ធិករ:Y

ឈ្មោះក្នុងគោលបញ្ជីដីធ្លី:Y



X

② ទាមទារដូចគ្នាម្តងទៀត

ទាមទារឱ្យចុះបញ្ជីផ្ទេរកម្មសិទ្ធិដោយ
ផ្អែកលើកិច្ចសន្យាលក់ទិញ

① ច្រានចោលនូវការ
ទាមទារ (ចូលជាស្ថាពរ)

ទាមទារឱ្យចុះបញ្ជីផ្ទេរកម្មសិទ្ធិដោយ
ផ្អែកលើកិច្ចសន្យាលក់ទិញ



Y

# អាជ្ញាអស់ជំនុំនៃសាលក្រម

តាមរយៈអានុភាពនៃអាជ្ញាអស់ជំនុំ តុលាការនៃបណ្ដឹងដែលត្រូវបានដាក់ក្រោយ មិនអាចធ្វើការវិនិច្ឆ័យផ្ទុយពីសាលក្រមដែលបានចេញចំពោះបណ្ដឹងដែលត្រូវបានដាក់មុននោះបានឡើយ។

ដើម្បីដោះស្រាយវិវាទតាមរយៈបណ្ដឹង ហើយចាំបាច់បង្ការកុំឱ្យមានការយកវិវាទដដែលជាដដែលមកតុលាការ ដូច្នេះហើយចាំបាច់ត្រូវមានអាជ្ញាអស់ជំនុំ។

---

មាត្រា194 កថាខ័ណ្ឌទី1
នៅពេលសាលក្រមចូលជាស្ថាពរហើយ អានុភាពនៃអាជ្ញាអស់ជំនុំត្រូវកើតឡើង ។

# អាជ្ញាអស់ជំនុំនៃសាលក្រម

អាជ្ញាអស់ជំនុំនឹងកើតមានឡើងទៅលើទំនាក់ទំនងសិទ្ធិ ឬទំនាក់ទំនងគតិយុត្តនៅថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់។

តើថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ គឺជាថ្ងៃណាមួយដែរ?

តើការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ គឺជាអ្វីដែរ?

---

មាត្រា194 កថាខ័ណ្ឌទី2

អាជ្ញាអស់ជំនុំដែលបានកំណត់ក្នុងកថាខ័ណ្ឌទី ១ ខាងលើនេះ ត្រូវកំណត់ជាស្ថាពរនូវទំនាក់ទំនងសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត នាពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ។

# ការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់

ការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់(មាត្រា 180 កថាខ័ណ្ឌទី1)

បើសិនជាធ្វើការផ្ទៀងផ្ទាត់នូវការអះអាង ឬភស្តុតាងជាដើម ហើយគិតឃើញថា អាចចេញសាលក្រមបាន តុលាការនឹងបញ្ចប់ការទាញហេតុផល។ បន្ទាប់មក នឹងចេញសាលក្រម។ ថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ គឺជាមូលដ្ឋាននៃអាជ្ញាអស់ជំនុំ។

គឺជាចំណុចដែលចាំបាច់ត្រូវតែសរសេរក្នុងលិខិតសាលក្រម(មាត្រា189 កថាខ័ណ្ឌទី1 ចំណុច ខ.)។

# ការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់

## សភាពការណ៍បន្ថែមនៃ "ករណីសិក្សារួម"

1 កញ្ញា 2016

កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់លើកទី១

ធ្វើការសាកសួរសាក្សី

1 តុលា 2016

កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់លើកទី២

X-Y : ដាក់ការអះអាងនិងភស្តុតាង

តុលាការ : បញ្ចប់ការទាញហេតុផល

1 ធ្នូ 2016

កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់លើកទី៣

តុលាការ : ប្រកាសសាលក្រម

# ការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់

ស្ដីពីករណីនេះ ថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ គឺ "ថ្ងៃទី1 ខែតុលា ឆ្នាំ2016"។

តាមរយៈការចូលជាស្ដាពរនៃសាលក្រមប្រានចោលនូវការទាមទាររបស់ X អាជ្ញាអស់ជំនុំខាងក្រោមនេះបានកើតមានឡើង។

"<u>នៅថ្ងៃទី1 ខែតុលា ឆ្នាំ2016</u> Xពុំមានសិទ្ធិទាមទារឱ្យ Y ចុះបញ្ជីផ្ទេរកម្មសិទ្ធិដោយផ្អែកលើកិច្ចសន្យាលក់ទិញចុះថ្ងៃទី1 ខែមករា ឆ្នាំ2016 ទេ។"

# ថ្ងៃដែលជាមូលដ្ឋាននៃអាជ្ញាអស់ជំនុំ

ហេតុអ្វីបានជាគេកំណត់ថ្ងៃដែលជាមូលដ្ឋាននៃអាជ្ញាអស់ជំនុំ ?

ដោយសារតែ នៅក្នុងបណ្តឹងដែលត្រូវបានដាក់ក្រោយ

1 ) គេហាមធ្វើការអះអាងពាក់ព័ន្ធនឹងអង្គហេតុដែលមានមុនថ្ងៃដែលជាមូលដ្ឋាន។

2 ) អាចអះអាងស្តីពីអង្គហេតុដែលកើតមានឡើងក្រោយថ្ងៃដែលជាមូលដ្ឋាន។

# ថ្ងៃដែលជាមូលដ្ឋាននៃអាជ្ញាអស់ជំនុំ

1 ) ការហាមនូវការអះអាងពាក់ព័ន្ធនឹងអង្គហេតុដែលមានមុនថ្ងៃដែលជាមូលដ្ឋាននៃអាជ្ញាអស់ជំនុំ

ភាគីអាចធ្វើការអះអាងនិងបញ្ជាក់ភស្តុតាងរហូតដល់ថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់បាន។
ហេតុនេះហើយ ភាគីអាចធ្វើការអះអាងអំពីអង្គហេតុដែលកើតមានឡើងមុនថ្ងៃនេះ នៅក្នុងបណ្តឹងដែលបានដាក់មុន។

ដូច្នេះ ទោះជាគេហាមធ្វើការអះអាងអំពីអង្គហេតុទាំងនេះនៅក្នុងបណ្តឹងដែលត្រូវបានដាក់ក្រោយក៏ដោយ ក៏មិនដឹងធ្វើម្តេចទេ ត្រូវតែទទួល។

# ថ្ងៃដែលជាមូលដ្ឋាននៃអាជ្ញាអស់ជំនុំ

2) <u>អាចធ្វើការអះអាងស្តីពីអង្គហេតុដែលកើតមានឡើងក្រោយថ្ងៃមូលដ្ឋាននៃអាជ្ញាអស់ជំនុំនេះ</u>

ស្តីពីអង្គហេតុដែលកើតមានឡើងក្រោយថ្ងៃមូលដ្ឋាននេះ ភាគីមិនអាចធ្វើការអះអាងក្នុងបណ្តឹងដែលត្រូវបានដាក់មុនបានទេ។

ពុំមានមូលហេតុអ្វីដែលត្រូវហាមធ្វើការអះអាងនៅក្នុងបណ្តឹងដែលគេបានដាក់ក្រោយទេ។

# ថ្ងៃដែលជាមូលដ្ឋាននៃអាជ្ញាអស់ជំនុំ

សូមលើកយក"ករណីសិក្សារួម"(បន្ថែម)មកពិចារណា។

បណ្តឹងដែលត្រូវបានដាក់មុន

- ថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់: ថ្ងៃទី 1 ខែតុលា ឆ្នាំ2016
- សាលក្រមច្រានចោលនូវការទាមទារ(ចូលជាស្ថាពរ)

បណ្តឹងដែលត្រូវបានដាក់ក្រោយ

- X→Y ដាក់ពាក្យបណ្តឹងដូចគ្នា
- ទាមទារឱ្យចុះបញ្ជីផ្ទេរកម្មសិទ្ធិដោយផ្អែកលើកិច្ចសន្យាលក់ទិញ

# ករណីសិក្សារួម(បន្ថែម)



ដី L

កម្មសិទ្ធិករ:Y

ឈ្មោះក្នុងគោលបញ្ជីដីធ្លី:Y



② ទាមទារដូចគ្នាម្តងទៀត

ទាមទារឱ្យចុះបញ្ជីផ្ទេរកម្មសិទ្ធិដោយផ្អែកលើកិច្ចសន្យាលក់ទិញ

① ប្រានចោលនូវការទាមទារ (ចូលជាស្ថាពរ)

ទាមទារឱ្យចុះបញ្ជីផ្ទេរកម្មសិទ្ធិដោយផ្អែកលើកិច្ចសន្យាលក់ទិញ

X



Y

# ថ្ងៃដែលជាមូលដ្ឋាននៃអាជ្ញាអស់ជំនុំ

អាជ្ញាអស់ជំនុំនៅក្នុងបណ្ដឹងដែលបានដាក់មុន

"នៅថ្ងៃទី1 ខែតុលា ឆ្នាំ2016 Xពុំមានសិទ្ធិទាមទារឱ្យ Y ចុះបញ្ជីផ្ទេរកម្មសិទ្ធិដោយផ្អែកលើកិច្ចសន្យាលក់ទិញចុះថ្ងៃទី1 ខែមករា ឆ្នាំ 2016 ទេ។"

ការអះអាងរបស់ X នៅក្នុងបណ្ដឹងដែលបានដាក់ក្រោយ

"នៅថ្ងៃទី1 ខែមករា ឆ្នាំ2016 ខ្ញុំពិតជាបានទិញដី L មែន។"

នេះគឺជាការអះអាងនូវអង្គហេតុដែលកើតមានឡើងមុនថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ (ថ្ងៃមូលដ្ឋាន : ថ្ងៃទី1 ខែតុលា ឆ្នាំ2016) ហេតុនេះហើយ ការអះអាងនេះត្រូវបានហាម។

# ថ្ងៃដែលជាមូលដ្ឋាននៃអាជ្ញាអស់ជំនុំ

## ន័យនៃ "ត្រូវបានហាម"

តាមធម្មតា តុលាការមិនអាចលើកយកការអះអាងនេះមកធ្វើជាការបានឡើយ។

នៅក្នុងបណ្តឹងដែលបានដាក់ក្រោយ តុលាការលើកយកតែការអះអាងណាដែលកើតមានឡើងក្រោយថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៃបណ្តឹងដែលបានដាក់មុនមកធ្វើការវិនិច្ឆ័យបានហើយ។

# ទំហំនៃអាជ្ញាអស់ជំនុំ

អាជ្ញាអស់ជំនុំមានត្រឹមតែទំហំដែលបានវិនិច្ឆ័យក្នុងសេចក្ដីសម្រេចបញ្ចប់ ចំពោះការទាមទារប៉ុណ្ណោះ។ មានន័យថា មានតែទៅលើទំនាក់ទំនងសិទ្ធិ ឬទំនាក់ទំនងគតិយុត្តិដែលបានទាមទារប៉ុណ្ណោះ។

ជាគោលការណ៍ អាជ្ញាអស់ជំនុំពុំមានចំពោះការវិនិច្ឆ័យនៅក្នុងការសំអាងហេតុនៃសាលក្រមទេ។

---

មាត្រា194 កថាខ័ណ្ឌទី3

ទំហំនៃអាជ្ញាអស់ជំនុំដែលបានកំណត់ក្នុងកថាខ័ណ្ឌទី ១ ខាងលើនេះ មានត្រឹមតែទំហំដែលបានវិនិច្ឆ័យនៅក្នុងសេចក្ដីសម្រេចបញ្ចប់ ចំពោះការទាមទារដែលបានសុំដោយពាក្យបណ្ដឹង ឬ ពាក្យបណ្ដឹងតបតែប៉ុណ្ណោះ ហើយអានុភាពនៃអាជ្ញាអស់ជំនុំនេះ មិនអាចមានទៅលើសេចក្ដីវិនិច្ឆ័យក្នុងសំអាងហេតុនៃសាលក្រមបានទេ។

# អានុភាពនៃអាជ្ញាអស់ជំនុំ

## “អានុភាពនៃអាជ្ញាអស់ជំនុំ”

1) តុលាការនៃបណ្តឹងដែលបានដាក់ក្រោយ ត្រូវយកការវិនិច្ឆ័យដែលមានអាជ្ញាអស់ជំនុំនៃបណ្តឹងដែលបានដាក់មុន មកធ្វើជាមូលដ្ឋាននៃការវិនិច្ឆ័យបណ្តឹងដែលបានដាក់ក្រោយ។

2) នៅក្នុងបណ្តឹងដែលបានដាក់ក្រោយ គេមិនអនុញ្ញាតឱ្យភាគីធ្វើការអះអាងអំពីអង្គហេតុដែលកើតមានឡើងមុនថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៃបណ្តឹងដែលបានដាក់មុនទេ។

3) គេមិនអនុញ្ញាតឱ្យតុលាការនៃបណ្តឹងដែលបានដាក់ក្រោយ លើកយកការអះអាងពាក់ព័ន្ធនឹងអង្គហេតុដែលកើតមានឡើងមុនថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៃបណ្តឹងដែលបានដាក់មុនឡើយ។

# អានុភាពនៃអាជ្ញាអស់ជំនុំ

## សូមយកករណីសិក្សាខ្លះៗមកពិចារណា។

"ឧទាហរណ៍ទី១"

បណ្ដឹងដែលបានដាក់មុន

- P→ D "បង្គាប់ឱ្យរើចេញ ហើយប្រគល់ដី"
- ទាមទារឱ្យប្រគល់ដីដោយផ្អែកលើកម្មសិទ្ធិ
- ថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់:ថ្ងៃទី 1 ខែធ្នូ ឆ្នាំ2015
- សាលក្រមច្រានចោលនូវការទាមទារ(ចូលជាស្ថាពរ)

បណ្ដឹងដែលបានដាក់ក្រោយ

- P→ D ដាក់ពាក្យបណ្ដឹងដូចគ្នា

# អានុភាពនៃអាជ្ញាអស់ជំនុំ

អាជ្ញាអស់ជំនុំក្នុងបណ្ដឹងដែលបានដាក់មុន

"នៅថ្ងៃទី1 ខែធ្នូ ឆ្នាំ2015 P ពុំមានសិទ្ធិទាមទារឱ្យDប្រគល់ដីវិញទេ។"

តុលាការនៃបណ្ដឹងដែលបានដាក់ក្រោយ ត្រូវធ្វើការវិនិច្ឆ័យ និងចេញសាលក្រមដោយផ្អែកលើអាជ្ញាអស់ជំនុំខាងលើនេះ។

បើសិនជាពុំមានអង្គហេតុណាមួយកើតឡើងក្រោយថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៃបណ្ដឹងដែលបានដាក់មុនទេ ត្រូវច្រានចោលនូវការទាមទារក្នុងបណ្ដឹងដែលបានដាក់ក្រោយដែរ។

# អានុភាពនៃអាជ្ញាអស់ជំនុំ

ការអះអាងរបស់ P នៅក្នុងបណ្តឹងដែលបានដាក់ក្រោយ

1) នៅថ្ងៃទី1 ខែមករា ឆ្នាំ2015 Pបានទិញដីពី Z ហើយបានចុះបញ្ជីផ្ទេរកម្មសិទ្ធិ។

2) នៅថ្ងៃទី1 ខែមករា ឆ្នាំ2016 Pបានទិញដីពី Z ហើយបានចុះបញ្ជីផ្ទេរកម្មសិទ្ធិ។

※ការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់គឺ ថ្ងៃទី1 ខែធ្នូ ឆ្នាំ 2015

ការអះអាងទី1) អង្គហេតុដែលបានកើតមានឡើង"មុន"ថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៃបណ្តឹងដែលបានដាក់មុន

→ ត្រូវបានហាម។

ការអះអាងទី2) អង្គហេតុដែលបានកើតមានឡើង"ក្រោយ"ថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៃបណ្តឹងដែលបានដាក់មុន

→ មិនត្រូវបានហាមទេ។

# អានុភាពនៃអាជ្ញាអស់ជំនុំ

"ឧទាហរណ៍ទី២"

បណ្ដឹងដែលបានដាក់មុន

- P→D "បញ្ជាក់ថា P មានកម្មសិទ្ធិលើដី"
- ទាមទារនូវការបញ្ជាក់កម្មសិទ្ធិលើដី
- ថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ : ថ្ងៃទី1 ខែធ្នូ ឆ្នាំ2015
- សាលក្រមទទួលស្គាល់ការទាមទារ(ចូលជាស្ថាពរ)

បណ្ដឹងដែលបានដាក់ក្រោយ

- P→D ដាក់ពាក្យបណ្ដឹងទាមទារឱ្យរើចេញនិងប្រគល់ដី

# អានុភាពនៃអាជ្ញាអស់ជំនុំ

អាជ្ញាអស់ជំនុំក្នុងបណ្តឹងដែលបានដាក់មុន

"នៅថ្ងៃទី1 ខែធ្នូ ឆ្នាំ2015 P មានកម្មសិទ្ធិលើដី។"

តុលាការនៃបណ្តឹងដែលបានដាក់ក្រោយ ត្រូវធ្វើការវិនិច្ឆ័យ និង ចេញសាលក្រមដោយផ្អែកលើអាជ្ញាអស់ជំនុំនេះ។

តាមរយៈអង្គហេតុដែលបានកើតមានឡើងក្រោយថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៃបណ្តឹងដែលបានដាក់មុន បើសិនជា P មិនបាត់បង់កម្មសិទ្ធិទេ តុលាការត្រូវធ្វើការវិនិច្ឆ័យដោយផ្អែកលើ P ជាកម្មសិទ្ធិករ។

# អានុភាពនៃអាជ្ញាអស់ជំនុំ

ការអះអាងរបស់ D នៅក្នុងបណ្តឹងដែលបានដាក់ក្រោយ

1) នៅថ្ងៃទី1 ខែមករា ឆ្នាំ2015 Dបានទិញដីពី Z ហើយបានចុះបញ្ជីផ្ទេរកម្មសិទ្ធិ។

2) នៅថ្ងៃទី1 ខែមករា ឆ្នាំ2016 Dបានទិញដីពី Z ហើយបានចុះបញ្ជីផ្ទេរកម្មសិទ្ធិ។

※ ការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់គឺ ថ្ងៃទី1 ខែធ្នូ ឆ្នាំ 2015

ការអះអាងទី1) អង្គហេតុដែលបានកើតមានឡើង"មុន"ថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៃបណ្តឹងដែលបានដាក់មុន

→ ត្រូវបានហាម។

ការអះអាទី2) អង្គហេតុដែលបានកើតមានឡើង"ក្រោយ"ថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៃបណ្តឹងដែលបានដាក់មុន

→ មិនត្រូវបានហាមទេ។

# អានុភាពនៃអាជ្ញាអស់ជំនុំ

"ឧទាហរណ៍ទី៣"

បណ្ដឹងដែលបានដាក់មុន

- P→D "បង្គាប់ឱ្យបង់ប្រាក់១ម៉ឺនដុល្លារអាមេរិក"
- ទាមទារដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគចុះថ្ងៃទី1 ខែមករា ឆ្នាំ2015
- ថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ : ថ្ងៃទី1 ខែធ្នូ ឆ្នាំ2015
- សាលក្រមច្រានចោលនូវការទាមទារ(ចូលជាស្ថាពរ)

បណ្ដឹងដែលបានដាក់ក្រោយ

- P→D ដាក់ពាក្យបណ្ដឹងដូចគ្នា

# អានុភាពនៃអាជ្ញាអស់ជំនុំ

អាជ្ញាអស់ជំនុំនៅក្នុងបណ្ដឹងដែលបានដាក់មុន

"នៅថ្ងៃទី1 ខែមករា ឆ្នាំ2015 Pពុំមានសិទ្ធិទាមទារឱ្យD សងប្រាក់១ម៉ឺនដុល្លារអាមេរិក ដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគចុះថ្ងៃទី1 ខែមករា ឆ្នាំ 2015 ទេ" ។

តុលាការនៃបណ្ដឹងដែលបានដាក់ក្រោយ ត្រូវធ្វើការវិនិច្ឆ័យនិងចេញសាលក្រមដោយផ្អែកលើអាជ្ញាអស់ជំនុំនេះ។

បើសិនជាពុំមានអង្គហេតុថ្មីក្រោយថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៃបណ្ដឹងដែលបានដាក់មុនទេ ត្រូវច្រានចោលការទាមទារនៃបណ្ដឹងដែលបានដាក់ក្រោយ។

# អានុភាពនៃអាជ្ញាអស់ជំនុំ

ការអះអាងរបស់ P ក្នុងបណ្តឹងដែលបានដាក់ក្រោយ

1) នៅថ្ងៃទី1 ខែមករា ឆ្នាំ2015 ខ្ញុំពិតជាបានប្រគល់ប្រាក់១ម៉ឺនដុល្លារអាមេរិកទៅឱ្យ D មែន។

2) នៅថ្ងៃទី1 ខែមករា ឆ្នាំ2016 ខ្ញុំពិតជាបានប្រគល់ប្រាក់១ម៉ឺនដុល្លារអាមេរិកទៅឱ្យ D មែន។

※ ការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់គឺ ថ្ងៃទី1 ខែធ្នូ ឆ្នាំ 2015

ការអះអាងទី1) អង្គហេតុដែលបានកើតមានឡើង"មុន"ថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៃបណ្តឹងដែលបានដាក់មុន

→ ត្រូវបានហាម។

ការអះអាងទី2) អង្គហេតុដែលបានកើតមានឡើង"ក្រោយ"ថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៃបណ្តឹងដែលបានដាក់មុន

→ មិនត្រូវបានហាមទេ។

# ការចាត់ចែងរបស់តុលាការ

បើសិនជាតុលាការនៃបណ្តឹងដែលបានដាក់ក្រោយ ចេញសាលក្រមផ្ទុយនឹងសាលក្រមដែលបានចូលជាស្ថាពររបស់តុលាការនៃបណ្តឹងដែលបានដាក់មុន ករណីនេះនឹងមានមូលហេតុនៃការជំនុំជម្រះសាជាថ្មី(មាត្រា307 កថាខ័ណ្ឌទី1 ចំណុច ញ)។

ការដាក់ពាក្យបណ្តឹងម្តងទៀតក្រោយពេលសាលក្រមចូលជាស្ថាពរ គឺជាការបង្កើតវិវាទដដែលឡើងវិញ ដូច្នេះមិនត្រឹមត្រូវទេ។

ក្នុងករណីដែលមានបណ្តឹងបែបនេះ តុលាការត្រូវធ្វើការវិនិច្ឆ័យ និង ចេញសាលក្រមឱ្យសមស្រប ដោយផ្អែកលើអាជ្ញាអស់ជំនុំនៃបណ្តឹងដែលបានដាក់មុន។

# បើសិនជាជួបករណីដូចខាងក្រោមនេះ តើត្រូវធ្វើដូចម្តេច ?

1 បើសិនជាពាក្យបណ្តឹងមានចំណុចខ្វះ

2 បើសិនជាមានការទាមទារបន្ថែម ក្រោយពេលដាក់ពាក្យបណ្តឹង

3 បើសិនជាខ្លឹមសារនៃការទាមទាររបស់ដើមចោទនៅក្នុងពាក្យបណ្តឹង សរសេរមិនបានត្រឹមត្រូវ

4 បើសិនជាមានការប្តឹងជាន់គ្នា ចំពោះរឿងក្តីតែមួយ

*5 បើសិនជាមានការដាក់ពាក្យសុំចាត់ចែងរក្សាការពារដ្ឋប្បវេណី ក្រោយពេលសាលក្រមសម្រេចអង្គសេចក្តីបានចូលជាស្ថាពរ*

6 បើសិនជា មិនមានការគោរពអំឡុងពេលប្តឹងឧបាស្រ័យទេ

5 បើសិនជាមានការដាក់ពាក្យសុំចាត់ចែងរក្សាការពាររដ្ឋប្បវេណី ក្រោយពេលសាលក្រមសម្រេចអង្គសេចក្ដីបានចូលជាស្ថាពរ

# ករណីសិក្សារួម



ដី L
　កម្មសិទ្ធិករ : Y
　ឈ្មោះក្នុងគោលបញ្ជីដីធ្លី : Y



អ្នកឯងត្រូវចុះបញ្ជីផ្ទេរកម្មសិទ្ធិ
ដីL មកឱ្យខ្ញុំ !
(ដាក់ពាក្យបណ្តឹង)



X → Y

ការទាមទារ : ការទាមទារឱ្យចុះបញ្ជីផ្ទេរកម្មសិទ្ធិ
ដោយផ្អែកលើការលក់ទិញ

# ការដាក់ពាក្យសុំឱ្យរក្សាការពារក្រោយពេលសាលក្រមបានចូលជាស្ថាពរ

## សភាពការណ៍បន្ថែមនៃ "ករណីសិក្សារួម"

តុលាការបានចេញសាលក្រមច្រានចោលនូវការទាមទាររបស់ X ហើយសាលក្រមនោះបានចូលជាស្ថាពរ។

ក្រោយមកទៀត X បានដាក់ពាក្យសុំឱ្យរក្សាការពារ គឺដាក់ពាក្យសុំឱ្យធ្វើការចាត់ចែងជាបណ្ដោះអាសន្នចំពោះ Y ហាមធ្វើការចាត់ ចែងដី L ។

តើអាចទទួលស្គាល់ពាក្យសុំនេះ ឬទេ?

# ករណីសិក្សារួម(បន្ថែម)



ដី L

កម្មសិទ្ធិករ:Y

ឈ្មោះក្នុងគោលបញ្ជីដីធ្លី:Y



② ដាក់ពាក្យសុំឱ្យរក្សាការពារ

ការចាត់ចែងជាបណ្ដោះអាសន្នហាម
ចាត់ចែងដី



X

① ច្រានចោលនូវការ
ទាមទារ (ចូលជាស្ថាពរ)

Y

ការទាមទារឱ្យចុះបញ្ជីផ្ទេរកម្មសិទ្ធិដោយ
ផ្អែកលើកិច្ចសន្យាលក់ទិញ

ពេលនេះ មាន"ពាក្យសុំឱ្យរក្សាការពារ" ក៏ប៉ុន្តែមិនជាអីទេ។ ចំណុចដែលត្រូវពិចារណាលើកនេះគឺមានដូចតទៅ៖

សិទ្ធិដែលត្រូវរក្សាការពារ = សិទ្ធិដែលទាមទារនៅក្នុងបណ្តឹងអង្គសេចក្តី("ការទាមទារ")

↓

<u>បើសិនជាសិទ្ធិដែលទាមទារនៅក្នុងបណ្តឹងអង្គសេចក្តីគ្មានអត្ថិភាពទេ សិទ្ធិដែលត្រូវរក្សាការពារក៏គ្មានដែរ។</u>

# ក៏ប៉ុន្តែបើសិនជាមិនសូវយល់អំពីការរក្សាការពារប្រហែលជាគិតឃើញថា ពិបាកក៏មិនដឹង។ ដូច្នេះ ខ្ញុំសូមពន្យល់សង្ខេបៗអំពីការរក្សាការពារ។

សេចក្តីពន្យល់នៅទីនេះ គឺគ្រាន់តែលើកយកចំណុចដែលចាំបាច់សម្រាប់ករណីសិក្សាលើកនេះមកពន្យល់ប៉ុណ្ណោះ។
ស្តីពីការរក្សាការពារ បើសិនជាលោកអ្នកចង់ដឹងលំអិតថែមទៀត សូមមើលឯកសារដែលប្រើក្នុងសិក្សាសាលានៅខែមករា ឆ្នាំ២០១៦ នៅភ្នំពេញ ស្តីពី "ការរក្សាការពារ"។
លោកអ្នកអាចដកយកឯកសារនេះពីគេហទំព័រខាងក្រោមនេះបាន។

The Legal and Judicial Development Project (Phase 4)
http://www.jica.go.jp/project/english/cambodia/014/index.html
http://www.jica.go.jp/project/english/cambodia/014/materials/index.html



# “ឯកសារយោង”

# សិក្ខាសាលានៅកម្ពុជា នាខែមករា ឆ្នាំ2016 “ការរក្សាការពាររដ្ឋប្បវេណី(ទ្រឹស្ដីទូទៅ)”

- មុខងារនៃការរក្សាការពារ ស្លៃដ៍ទី17
- លក្ខណៈពិសេសនៃការរក្សាការពារ ស្លៃដ៍ទី18～19
- ប្រភេទនៃការរក្សាការពារ ខ្លឹមសារ ស្លៃដ៍ទី26～30

# ការដាក់ពាក្យសុំរក្សាការពារក្រោយពេលសាលក្រមចូលជាស្ថាពរ

ការចាត់ចែងជាបណ្ដោះអាសន្នក៏ជាការរក្សាការពារមួយដែរ។ ហេតុនេះហើយ  នេះគឺជា "វិធីសង្គ្រោះបណ្ដោះអាសន្ន" រហូតដល់ពេលអាចធ្វើការអនុវត្តដោយបង្ខំបាន តាមរយៈសាលក្រមឈ្នះក្ដីក្នុងបណ្ដឹងអង្គសេចក្ដី។

នៅក្នុង "ករណីសិក្សារួម" សាលក្រមដែល X ចាញ់ក្ដី (ច្រានចោលនូវការទាមទារ) បានចូលជាស្ថាពរ។

តើតុលាការចាំបាច់ទទួលស្គាល់នូវ "វិធីសង្គ្រោះជាបណ្ដោះអាសន្ន" ជាថ្មីទៀត សម្រាប់ X ដែរឬទេ ?

# ការដាក់ពាក្យសុំរក្សាការពារក្រោយពេលសាលក្រមចូលជាស្ថាពរ

ចូរពិចារណាអំពីល័ក្ខខ័ណ្ឌនៃការចាត់ចែងជាបណ្ដោះអាសន្ន។

1) សិទ្ធិដែលត្រូវរក្សាការពារ(មាត្រា541 កថាខ័ណ្ឌទី1 ចំណុច គ)
2) ភាពចាំបាច់នៃការរក្សាការពារ(កថាខ័ណ្ឌដដែល ចំណុច ឃ)

សិទ្ធិដែលត្រូវរក្សាការពារនៃពាក្យសុំរបស់ X គឺ ៖

"សិទ្ធិទាមទារឱ្យចុះបញ្ជីផ្ទេរកម្មសិទ្ធិដី L ដោយផ្អែកលើកិច្ចសន្យាលក់ទិញ ចុះថ្ងៃទី1 ខែមករា ឆ្នាំ2016"

=សិទ្ធិទាមទារក្នុងបណ្ដឹងអង្គសេចក្ដី("ការទាមទារ")

# ការដាក់ពាក្យសុំរក្សាការពារក្រោយពេលសាលក្រមចូលជាស្ថាពរ

សាលក្រមដែល X ចាញ់ក្តី(ច្រានចោលនូវការទាមទារ) បានចូលជាស្ថាពរ។

នៅថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់(ថ្ងៃទី1 ខែតុលា 2016) នត្តិភាពនៃ “សិទ្ធិទាមទារឱ្យចុះបញ្ជីផ្ទេរកម្មសិទ្ធិដី L ដោយផ្អែកលើកិច្ចសន្យាលក់ទិញចុះថ្ងៃទី1 ខែមករា ឆ្នាំ2016” បានចូលជាស្ថាពរ។

សិទ្ធិដែលត្រូវរក្សាការពារពុំមានទេ ដូច្នេះ ត្រូវលើកចោលពាក្យសុំរក្សាការពាររបស់ X (ជាគោលការណ៍)។

# ការដាក់ពាក្យសុំរក្សាការពារក្រោយពេលសាលក្រមចូលជាស្ថាពរ

ក៏ប៉ុន្តែ ភាគច្រើន តុលាការដែលទទួលបន្ទុកពាក្យសុំរក្សាការពាររបស់ X មិនបានដឹងអំពីសាលក្រមចាញ់ក្តីរបស់ X (ច្រានចោលនូវការទាមទារ) ចូលជាស្ថាពរនោះទេ។

- ដោយសារតែក្រៅពីករណីចាត់ចែងជាបណ្តោះអាសន្នកំណត់ឋានៈជាបណ្តោះអាសន្ន ជាគោលការណ៍ មិនឆ្លងកាត់ការសួរ Y ទេ (សូមមើលមាត្រា548 កថាខ័ណ្ឌទី2, កថាខ័ណ្ឌទី4)។

ហេតុនេះហើយ តុលាការអាចមិនដឹងរឿងនេះ ហើយក៏ចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន តាមពាក្យសុំរបស់ X ។

# ការដាក់ពាក្យសុំរក្សាការពារក្រោយពេលសាលក្រមចូលជាស្ថាពរ

បន្ទាប់មក  Y ដែលបានដឹងថា មានដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នចំពោះគាត់ តើគាត់ត្រូវធ្វើដូចម្ដេចដែរ ?

Yត្រូវតែ<u>ដាក់ពាក្យសុំតវ៉ា</u>ចំពោះដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន (ដីកាសម្រេចរក្សាការពារ) (មាត្រា550)។
ព្រមជាមួយគ្នានេះ Y ក៏ត្រូវទាមទារសុំឱ្យ<u>ផ្អាកការអនុវត្តរក្សាការពារ</u> ដើម្បីកុំឱ្យគេអនុវត្តដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន(មាត្រា551)។

# ការដាក់ពាក្យសុំរក្សាការពារក្រោយពេលសាលក្រមចូលជាស្ថាពរ

លំអិតគឺ Y ត្រូវធ្វើការអះអាង និងបញ្ជាក់ភស្តុតាងថា ខ្លួនបានទទួល “សាលក្រមស្ថាពរដែល X ចាញ់ (ច្រានចោលការទាមទារ)” តាមរយៈនីតិវិធីនៃបណ្តឹងតវ៉ា។

ធ្វើដូច្នេះទៅ គេអាចដឹងថា សិទ្ធិដែលទាមទារក្នុងបណ្តឹងអង្គសេចក្តីគ្មានអត្ថិភាពទេ ដូច្នេះ ពុំមានសិទ្ធិដែលត្រូវរក្សាការពារទេ។

# ការដាក់ពាក្យសុំរក្សាការពារក្រោយពេលសាលក្រមចូលជាស្ថាពរ

## នីតិវិធីតវ៉ាចំពោះដីកាសម្រេចរក្សាការពារ

- ត្រូវធ្វើការវិនិច្ឆ័យអំពីអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុដែលកើតមានឡើង ក្រោយថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់(ថ្ងៃទី1 ខែតុលា ឆ្នាំ2016)។

- បើសិនជាពុំមានការបញ្ជាក់ដំបូងអំពីអត្ថិភាពនៃសិទ្ធិដែលត្រូវរក្សាការពារទេ(មាត្រា541 កថាខ័ណ្ឌទី1 ចំណុច គ) តុលាការត្រូវលុបចោលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នចោល (មាត្រា 554 កថាខ័ណ្ឌទី1)។

# ការដាក់ពាក្យសុំរក្សាការពារក្រោយពេលសាលក្រមចូលជាស្ថាពរ

សភាពការណ៍បន្ថែមនៃ "ករណីសិក្សារួម"

បើសិនជាសាលក្រមឈ្នះក្តីរបស់ X បានចូលជាស្ថាពរ តើត្រូវធ្វើយ៉ាងដូចម្តេចដែរ ?

# ករណីសិក្សារួម(បន្ថែម)



ដី L

កម្មសិទ្ធិករ:Y

ឈ្មោះក្នុងគោលបញ្ជីដីធ្លី:Y



X

② ដាក់ពាក្យសុំរក្សាការពារ

ចាត់ចែងជាបណ្តោះអាសន្នហាមការ
ចាត់ចែងដី

① ទទួលស្គាល់ការ
ទាមទារ(ចូលជាស្ថាពរ)

ទាមទារឱ្យចុះបញ្ជីផ្ទេរកម្មសិទ្ធិដោយ
ផ្អែកលើកិច្ចសន្យាលក់ទិញ



Y

# ការដាក់ពាក្យសុំរក្សាការពារក្រោយពេលសាលក្រមចូលជាស្ថាពរ

X អាចចុះបញ្ជីផ្ទេរកម្មសិទ្ធិភ្លាមបានដោយផ្អែកលើសាលក្រមស្ថាពរទទួលស្គាល់ការទាមទារ។

ដូច្នេះ គ្មានភាពចាំបាច់រក្សាការពារទេ(មាត្រា 541 កថាខ័ណ្ឌទី1 ចំណុច ឃ)។

តុលាការត្រូវលើកចោលនូវពាក្យសុំរក្សាការពាររបស់ X។

# បើសិនជាជួបករណីដូចខាងក្រោមនេះ តើត្រូវធ្វើដូចម្តេច ?

1 បើសិនជាពាក្យបណ្តឹងមានចំណុចខ្វះ

2 បើសិនជាមានការទាមទារបន្ថែម ក្រោយពេលដាក់ពាក្យបណ្តឹង

3 បើសិនជាខ្លឹមសារនៃការទាមទាររបស់ដើមចោទនៅក្នុងពាក្យបណ្តឹង សរសេរមិនបានត្រឹមត្រូវ

4 បើសិនជាមានការប្តឹងជាន់គ្នា ចំពោះរឿងក្តីតែមួយ

5 បើសិនជាមានការដាក់ពាក្យសុំចាត់ចែងរក្សាការពាររដ្ឋប្បវេណី ក្រោយពេលសាលក្រមសម្រេចអង្គសេចក្តីបានចូលជាស្ថាពរ

*6 បើសិនជា មិនមានការគោរពអំឡុងពេលប្តឹងឧបាស្រ័យទេ*

6 បើសិនជា មិនមានការគោរពអំឡុងពេលប្ដីងឧបាស្រ័យទេ

# ករណីសិក្សារួម



ដី L

កម្មសិទ្ធិករ : Y

ឈ្មោះក្នុងគោលបញ្ជីដីធ្លី : Y



X



Y

ប្រានចោលនូវការទាមទារ (ចូលជាស្ថាពរ)

ទាមទារឱ្យចុះបញ្ជីផ្ទេរកម្មសិទ្ធិ
ដោយផ្អែកលើកិច្ចសន្យាលក់ទិញ

# ការប្ដឹងឧបាស្រ័យ

<u>សភាពការណ៍បន្ថែមនៃ "ករណីសិក្សារួម"</u>

តុលាការបានបញ្ជូនលិខិតសាលក្រមប្រានចោលការទាមទារដូចខាងក្រោមនេះ។

តើអំឡុងពេលប្ដឹងឧទ្ធរណ៍របស់ X មានដល់ពេលណា ?

1 ធ្នូ 2016 — ប្រកាសសាលក្រមប្រានចោលការទាមទារ

10 ធ្នូ 2016 — បញ្ជូនលិខិតសាលក្រមទៅឱ្យ X

# ករណីសិក្សារួម (បន្ថែម)



ថ្ងៃទី 1 ខែធ្នូ ឆ្នាំ 2016
ប្រកាសសាលក្រម

សាលាដំបូង A



X

ថ្ងៃទី 10 ខែធ្នូ ឆ្នាំ 2016
បញ្ជូនទៅឱ្យ X

ច្រានចោលនូវការទាមទារ (ចូលជាស្ថាពរ)



Y

ទាមទារឱ្យចុះបញ្ជីផ្ទេរកម្មសិទ្ធិ
ដោយផ្អែកលើកិច្ចសន្យាលក់ទិញ

# ការប្តឹងឧបាស្រ័យ

បណ្តឹងឧទ្ធរណ៍ត្រូវធ្វើនៅក្នុងអំឡុងពេលមួយខែ ដោយគិតចាប់តាំងពីថ្ងៃដែលបានទទួលការបញ្ជូនលិខិតសាលក្រម(មាត្រា264 កថាខ័ណ្ឌទី1)។

ការគណនាអំឡុង "ពេល១ខែ" ត្រូវធ្វើតាមបញ្ញត្តិពាក់ព័ន្ធនឹងអំឡុងពេលនៃក្រមរដ្ឋប្បវេណី(មាត្រា 243 កថាខ័ណ្ឌទី1)។
លំអិតគឺ ក្រមរដ្ឋប្បវេណី មាត្រា334 និង មាត្រា335។

# ការប្តឹងឧបាស្រ័យ

**មាត្រា ៣៣៤.- ការគណនាអំឡុងពេលជាថ្ងៃ សប្តាហ៍ ខែ ឬ ឆ្នាំ**

១-ប្រសិនបើបានកំណត់អំឡុងពេលជាថ្ងៃ សប្តាហ៍ ខែ ឬ ឆ្នាំវិញ មិនត្រូវគិតបញ្ចូលថ្ងៃដែលចាប់ផ្តើមនៃអំឡុងពេលនេះទេ លើកលែងតែអំឡុងពេលនេះបានចាប់ផ្តើមពីម៉ោងសូន្យទៅ ។

២-ក្នុងករណីដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះ អំឡុងពេលត្រូវចប់ពេញលេញនៅពេលផុតថ្ងៃចុងក្រោយនៃអំឡុងពេលនោះ ។

៣-ប្រសិនបើថ្ងៃចុងក្រោយនៃអំឡុងពេលត្រូវជាថ្ងៃបុណ្យ ថ្ងៃអាទិត្យ ឬ ថ្ងៃឈប់សម្រាកផ្សេងទៀតដែលច្បាប់ ឬ បទដ្ឋានគតិយុត្តបានកំណត់អំឡុងពេលត្រូវចប់ពេញលេញនៅពេលផុតថ្ងៃធ្វើការបន្ទាប់ពីថ្ងៃឈប់នោះ ។

**មាត្រា ៣៣៥.- ការគណនាអំឡុងពេលតាមប្រតិទិនសុរិយគតិ**

១-ក្នុងករណីដែលធ្វើការគណនាអំឡុងពេលជាសប្តាហ៍ ខែ ឬ ឆ្នាំ ត្រូវធ្វើការគណនាតាមប្រតិទិនសុរិយគតិ ។

២-ក្នុងករណីដែលមិនធ្វើការគណនាអំឡុងពេលដោយគិតពីដើមសប្តាហ៍ ដើមខែ ឬ ដើមឆ្នាំទេ អំឡុងពេលនេះត្រូវចប់ពេញលេញនៅមួយថ្ងៃមុនថ្ងៃដែលត្រូវនឹងថ្ងៃចាប់ផ្តើមរាប់នៃសប្តាហ៍ចុងក្រោយ ខែចុងក្រោយ ឬ ឆ្នាំចុងក្រោយនៃអំឡុងពេល។ ប៉ុន្តែ ក្នុងករណីដែលត្រូវគណនាអំឡុងពេលជាខែ ឬ ជាឆ្នាំវិញ ប្រសិនបើខែ ឬ ឆ្នាំចុងក្រោយនៃអំឡុងពេលនោះ គ្មានថ្ងៃដែលត្រូវនឹងថ្ងៃដែលអំឡុងពេលបានចាប់ផ្តើមទេ ថ្ងៃចុងក្រោយនៃខែនោះត្រូវជាថ្ងៃដែលអំឡុងពេលត្រូវចប់ពេញលេញ។

"អំឡុងពេលប្តឹងឧបាស្រ័យ"

<u>ការប្តឹងឧទ្ធរណ៍</u> ត្រូវធ្វើនៅក្នុងអំឡុងពេល១ខែ ដោយគិតចាប់តាំងពីថ្ងៃ ដែលបានទទួលការបញ្ជូនលិខិតសាលក្រម ឬ ថ្ងៃដែលបានជូនដំណឹងអំពីដីកាសម្រេចច្រានចោល ឬ លើកចោលនូវបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ (មាត្រា264)

<u>ការប្តឹងសាទុក្ខ</u> ដូចគ្នានឹងការប្តឹងឧទ្ធរណ៍ដែរ(មាត្រា286)

<u>ការប្តឹងជំទាស់</u> មួយសប្តាហ៍ ដោយគិតចាប់ពីថ្ងៃដែលបានទទួលដំណឹងអំពីដីកាសម្រេច(មាត្រា303)

<u>ការជំនុំជម្រះសាជាថ្មី</u> ៣០ថ្ងៃ ដោយគិតចាប់ពីថ្ងៃដែលភាគីបានដឹងអំពីមូលហេតុនៃការជំនុំជម្រះសាជាថ្មី ក្រោយពេលដែលសាលក្រម ឬ សាលដីកាបានចូលជាស្ថាពរ(មាត្រា311)

※ក្នុងករណីដែលអំឡុងពេលនេះបានកន្លងផុតទៅ តុលាការត្រូវចេញសាលក្រម ឬ ដីកាសម្រេចថា បណ្តឹងនោះខុសច្បាប់ ហើយលើកច្រានបណ្តឹងនោះ(មាត្រា268, មាត្រា290, មាត្រា304, មាត្រា310)

# ការប្តឹងឧបាស្រ័យ

ថ្ងៃដំបូង : ថ្ងៃទី10 ខែធ្នូ ឆ្នាំ2016

→មិនរាប់បញ្ចូលទេ(ក្រមរដ្ឋប្បវេណី មាត្រា334 កថាខ័ណ្ឌទី1)។

ថ្ងៃចាប់ផ្តើមគណនា : ថ្ងៃទី11 ខែធ្នូ ឆ្នាំ2016

ថ្ងៃដែលត្រូវនឹងថ្ងៃចាប់ផ្តើមរាប់(១ខែក្រោយ):ថ្ងៃទី11 ខែមករា ឆ្នាំ2017

មួយថ្ងៃមុនថ្ងៃដែលត្រូវនឹងថ្ងៃចាប់ផ្តើមរាប់:ថ្ងៃទី10 ខែមករា ឆ្នាំ2017

តាមរយៈការចប់នៃ"ថ្ងៃទី10 ខែមករា ឆ្នាំ2017" អំឡុងពេលត្រូវបានចប់(ក្រមរដ្ឋប្បវេណី មាត្រា335 កថាខ័ណ្ឌទី2)។

# ការប្តឹងឧបាស្រ័យ

X ត្រូវធ្វើនីតិវិធីប្តឹងឧទ្ធរណ៍ត្រឹមថ្ងៃទី10 ខែមករា ឆ្នាំ2017 (រហូតដល់ពេលប្តូរទៅថ្ងៃទី11)។

នីតិវិធីនៃបណ្តឹងឧទ្ធរណ៍

- ដាក់ពាក្យបណ្តឹងឧទ្ធរណ៍ ទៅតុលាការដែលបានចេញសាលក្រម(សាលាដំបូង A)(មាត្រា265 កថាខ័ណ្ឌទី1)។
- ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹងឧទ្ធរណ៍(មាត្រា 265 កថាខ័ណ្ឌទី2)
  - ឈ្មោះ និងអាស័យដ្ឋានរបស់ភាគី ជាដើម
  - សញ្ញាណនៃសាលក្រមនៃការជំនុំជម្រះលើកទី១
  - សេចក្តីដែលប្តឹងឧទ្ធរណ៍

# ការប្តឹងឧបាស្រ័យ

ក្នុងករណីដែល X បានដាក់ពាក្យប្តឹងឧទ្ធរណ៍នៅថ្ងៃទី15 ខែមករា ឆ្នាំ2017  តើយ៉ាងណាដែរ ?

ជាបឋម  សាលាដំបូង A ត្រូវបញ្ជូនពាក្យបណ្តឹងឧទ្ធរណ៍ និង សំណុំរឿងប្តឹងឧទ្ធរណ៍ទៅសាលាឧទ្ធរណ៍(មាត្រា265 កថាខ័ណ្ឌទី1)។

- ទោះជាបណ្តឹងនោះមិនស្របច្បាប់ក៏ដោយ  សាលាដំបូងមិនអាចចាត់ចែងបណ្តឹងឧទ្ធរណ៍នោះ ដូចជាលើកបណ្តឹងចោល ជាដើម បានឡើយ។

# ការប្ដឹងឧបាស្រ័យ

បណ្ដឹងឧទ្ធរណ៍របស់ X ត្រូវបានដាក់ក្រោយពេលអំឡុងពេលអាចប្ដឹងឧទ្ធរណ៍បានកន្លងផុតទៅ ដូច្នេះមិនស្របច្បាប់។ ចំណុចខ្វះនេះមិនអាចកែតម្រូវបានឡើយ។

សាលាឧទ្ធរណ៍អាចលើកបណ្ដឹងឧទ្ធរណ៍ចោលបានដោយសាលដីកា(មាត្រា268)។

- ចំពោះសាលដីកាលើកបណ្ដឹងឧទ្ធរណ៍នេះចោលX អាចប្ដឹងសាទុក្ខបាន។

# ការចូលជាស្ថាពរនៃសាលដីកា

សាលដីកានឹងចូលជាស្ថាពរតាមរយៈការកន្លងផុតទៅនៃអំឡុងពេលប្តឹងទៅតុលាការជាន់ខ្ពស់ ឬសាលដីកានៃការជម្រះបណ្តឹងនៅតុលាការជាន់ខ្ពស់ ជាដើម(មាត្រា193)។

អាជ្ញាអស់ជំនុំ និង អានុភាពអនុវត្តនឹងកើតមានឡើងតាមរយៈការចូលជាស្ថាពរនៃសាលដីកា(មាត្រា194, មាត្រា195)។ ពេលណាចូលជាស្ថាពរម្តងហើយ មិនអាចមានវិវាទពាក់ព័ន្ធនឹងអានុភាពអនុវត្តបានឡើយ។

# ការចូលជាស្ថាពរនៃសាលដីកា និងការជំនុំជម្រះសាជាថ្មី

មានករណីលើកលែង គឺការជំនុំជម្រះសាជាថ្មី ដែលជារបបវិវាទអំពីអានុភាពនៃសាលដីកា។

- មានរបបផ្អាកការអនុវត្តដោយបង្ខំតាមរយៈការដាក់ពាក្យបណ្តឹងសុំឱ្យជំនុំជម្រះសាជាថ្មី(មាត្រា366)។
  ក៏ប៉ុន្តែ ការជំនុំជម្រះសាជាថ្មី គឺជារបបលើកលែងពិសេសណាស់ ដូច្នេះមិនត្រូវទទួលស្គាល់នូវការផ្អាកការអនុវត្តដោយបង្ខំងាយស្រួលឡើយ។

មូលហេតុនៃការជំនុំជម្រះសាជាថ្មី(មាត្រា307, មាត្រា308) ក៏ត្រូវបានកម្រិតតឹងរ៉ឹងណាស់ គឺមានតែករណីដែលមានបញ្ហាធ្ងន់ធ្ងរក្នុងបណ្តឹងដែលពាក់ព័ន្ធនឹងសាលដីកាដែលចូលជាស្ថាពរនោះប៉ុណ្ណោះ។

# ការចូលជាស្ថាពរនៃសាលដីកា និងការជំនុំជម្រះសាជាថ្មី

តាមធម្មតា តាមរយៈការចូលជាស្ថាពរនៃសាលក្រម ឬសាលដីកានេះ គេធ្វើការដោះស្រាយវិវាទឱ្យបានជាក់លាក់ ដើម្បីបង្ការកុំឱ្យមានការលើកយកវិវាទមកឱ្យតុលាការវិនិច្ឆ័យដដែលជាដដែល។
ក៏ប៉ុន្តែ បើសិនជាសាលដីកាចូលជាស្ថាពរទៅ ដាច់ខាតមិនអាចតវ៉ាបានទេ ពេលមានកំហុសដ៏ធ្ងន់ធ្ងរក្នុងការវិនិច្ឆ័យ គឺអយុត្តិធម៌ណាស់។

ហេតុនេះហើយបានជា គេបានបង្កើតរបបធ្វើការវិនិច្ឆ័យសាជាថ្មី (ការជំនុំជម្រះសាជាថ្មី) ដែលជាករណីលើកលែងដ៏ពិសេស។

ត្រូវតែប្រើរបបនេះទៅតាមគោលគំនិតនៃការបង្កើតរបបនេះ។

- ត្រូវតែចៀសវាងនូវការប្រើរបបជំនុំជម្រះសាជាថ្មីនេះដោយបំពាន ដោយគ្រាន់តែលើកយកវិវាទដដែលមកឱ្យតុលាការវិនិច្ឆ័យ។





# សូមអរគុណចំពោះការយកចិត្តទុកដាក់របស់លោកអ្នក។

International Cooperation Department
Research and Training Institute
Ministry of Justice of Japan

4th Floor, Osaka Nakanoshima National Government Building,
1-1-60 Fukushima, Fukushima-ku, Osaka City 553-0003
Phone: 81-6-4796-2153 Fax: 81-4796-2157
E-mail: icdmoj@moj.go.jp